# ការប្រទានអំណាចរបស់ព្រះ សម្រាប់ការប្រោសឱ្យជា



**លោកដុកទ័រ អេអែល ហ្គីល** គឺជាកំពូលអ្នកនិពន្ធសៀវភៅជិត២០ លានក្បាល ដែលបានបោះពុម្ពហើយ ។ ការងារជាសាវ័កផ្នែកអន្តរជាតិរបស់គាត់នេះ គឺបានចាប់យកមនុស្សជាង៨០ជនជាតិ ។ គាត់បានអធិប្បាយទៅដល់ហ្វូងមនុស្សជាងម្ភៃម៉ឺននាក់ ដោយមានការបញ្ជាក់មកពីព្រះ និងព្រះបន្ទូលរបស់ព្រះអង្គ ជាមួយនឹងទីសម្គាល់នៃការប្រោសឱ្យជា និងការអស្ចារ្យផ្សេងៗ ។ ការអនុវត្តន៍ដែលមានពេញដោយអំណាចចេស្តារបស់គាត់ សេចក្តីបង្រៀនដែលមានពេញដោយជីវិតផ្លាស់ប្រែ និងដែលមានលទ្ធភាព នោះគឺតាមរយៈវីឌីអូ អូឌីយ៉ូ និងសៀវភៅជាច្រើនភាសា នោះសូមមើលទៅក្នុងវ៉ិបសាយ:www.gillministries.com

*១. ការរំឭករបស់ព្រះពីភាពមានជម្ងឺ និងជម្ងឺរោគា..... ២២៧*
*២. ព្រះយេស៊ូវ ទ្រង់គឺជាអ្នកប្រោសឱ្យជារបស់យើង.. ២៣៩*
*៣. ព្រះយេស៊ូវ ទ្រង់គឺជាគំរូរបស់យើង.................. ២៤៥*
*៤. ព្រះវិញ្ញាណបរិសុទ្ធ និងអំណាចចេស្តារបស់ទ្រង់ ... ២៥៥*
*៥. ព្រះវិញ្ញាណបរិសុទ្ធសម្រាប់គ្រប់អ្នកជឿទាំងអស់.. ២៦១*
*៦. ការបំពេញការងារដោយនូវអំណាចចេស្តា........... ២៦៩*
*៧. ការបំពេញការងារតាមរយៈសកម្មភាពអធិស្ឋាន.. ២៧៧*
*៨. ការបាត់សម គឺអាចជួយដល់ការបំពេញការងារ.. ២៨៣*

# ការប្រទានអំណាចរបស់ព្រះ សម្រាប់ការប្រោសឱ្យជា

## *មេរៀនទី ១: ការរំឭករបស់ព្រះពីភាពមានជម្ងឺ និងជម្ងឺរោគា*

### I. សេចក្តីផ្តើម

### ក. ចំណុចនៃការរំឭករបស់ព្រះ

ជួនកាល នៅពេលដែលការសិក្សាគឺជាប្រធានបទមួយដែលវាគឺជាការប្រសើរបំផុត ដើម្បីឱ្យបានត្រឡប់មកវិញ និងបានគ្រឡេកមើលមកពីចំណុច នៃការរំឭករបស់ព្រះនោះ ។ តើព្រះទ្រង់មានអារម្មណ៍យ៉ាងណា អំពីជម្ងឺ និងជម្ងឺរោគានេះ?

នៅក្នុងការសិក្សានេះយើងនឹងមើលឃើញថា ការប្រោសឱ្យជា និងការមានសុខភាព គឺជាផ្នែកនៃផែនការរបស់ព្រះតាមរយៈព្រះគម្ពីរ និងជាការបន្តទៅគ្រប់ផ្នែកជាច្រើនទៀតនៃផែនការរបស់ព្រះ សម្រាប់ជីវិត និងការបំពេញការងារជារបស់យើងនោះ ។

ការប្រោសឱ្យជាគឺជាសេចក្តីសន្យាមួយរបស់ព្រះ ។ នៅពេលដែលយើងជឿ និងប្រព្រឹត្តតាមសេចក្តីសន្យាណាមួយក្នុងការបញ្ចេញនូវអំណាចចេស្តារបស់ព្រះ នៅក្នុងជីវិតរបស់យើង ។ យើងត្រូវតែរកឱ្យឃើញ នូវសេចក្តីសន្យារបស់ទ្រង់ចូរជឿលើការទាំងនោះ ហើយប្រព្រឹត្តតាមចុះ ។

ហើយលោកអ្នកត្រូវតែស្គាល់នូវសេចក្តីពិត ហើយសេចក្តីពិតក៏នឹងធ្វើឱ្យលោកអ្នក មានសេរីភាពផងដែរ (យ៉ូហាន ៨:៣២) ។

ព្រះគម្ពីរសុភាសិត ៤:២០-២២

**ខ. ប្រភពនៃជម្ងឺ**

ប្រសិនបើយើងជឿនូវជម្ងឺថាអាចចេញមកពីព្រះ នោះយើងនឹងមិនមានលទ្ធភាពជឿលើទ្រង់ឡើយ សម្រាប់ការធ្វើការប្រោសឱ្យជានោះ ។ ចំពោះហេតុផលនេះ គឺយើងត្រូវការយល់ដឹងពីប្រភពនៃជម្ងឺនោះ ។

**II. ការសំខាន់នៃការប្រោសឱ្យជា**

**ក. ការសំខាន់ចំពោះព្រះ**

ព្រះគម្ពីរនិក្ខមនំ ១៥:២៦ខ

ប្រសិនបើយើងមិនស្គាល់ដល់ព្រះអម្ចាស់ ដ៏ជាអ្នកប្រោសយើងឱ្យជានោះទេ នោះយើងមានការបាត់បង់នូវភាពសំខាន់ជាចម្បងនៃការប្រកបទាក់ទងរបស់យើង ជាមួយនឹងទ្រង់ហើយ ។ ការប្រោសឱ្យជាគឺជាការសំខាន់ចំពោះព្រះដ៏ជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធនោះឯង ។

**១. ព្រះវរបិតា**

ព្រះវិញ្ញាណបរិសុទ្ធ បានបណ្តាលលោកសាវ័កយ៉ូហាន ឱ្យបានសរសេរប្រាប់យើងពីការប្រោសឱ្យជានោះ គឺជាបំណងព្រះហឫទ័យនៃព្រះវរបិតានោះឯង ។

ព្រះគម្ពីរ ៣យ៉ូហាន ខ.២

វាគឺជាការចាំបាច់ ដែលយើងយល់ពីការប្រោសឱ្យជា គឺតែងតែជាបំណងព្រះហឫទ័យរបស់ព្រះ ។

នៅក្នុងការប្រោសអ្នកជម្ងឺឱ្យជារបស់ព្រះយេស៊ូវ នោះគឺទ្រង់កំពុងតែបានធ្វើ ទៅតាមបំណងព្រះហឫទ័យ នៃព្រះវរបិតាហើយ ។ វាគឺត្រូវបានកត់ត្រាដែលព្រះយេស៊ូវទ្រង់បានមានព្រះបន្ទូលនោះ ។

ព្រះគម្ពីរយ៉ូហាន ៦:៣៨

**២. ព្រះរាជបុត្រា**

ពេលដែលយើងដើរតាមព្រះយេស៊ូវ តាមរយៈការផ្សាយដំណឹងល្អ នោះយើងរកឃើញថា ទ្រង់បានបំពេញព្រះរាជកិច្ចក្នុងការប្រោសឱ្យជាពីស្ថានការណ៍ផ្សេងគ្នាជាច្រើន ។ សេចក្តីមេត្តាករុណារបស់ព្រះអង្គ សម្រាប់អ្នកមានជម្ងឺ នោះគឺជាព្រឹត្តិការណ៍ដ៏មាំមួន ។ ការប្រោសឱ្យជាគឺជាផ្នែកមួយដ៏ធំ នៃព្រះរាជកិច្ចជារបស់ផងទ្រង់ហើយ ។

ព្រះគម្ពីរម៉ាកុស ១:៤០-៤១

ការប្រោសឱ្យជា គឺជាការសំខាន់ចំពោះព្រះយេស៊ូវ គឺពីព្រោះតែទ្រង់បានយាងមកធ្វើការងារទៅតាមបំណងព្រះហឫទ័យនៃព្រះវរបិតា ។

ព្រះគម្ពីរហេព្រើរ ១០:៧

នៅពេលដែលព្រះយេស៊ូវ ទ្រង់បានយាងចេញពីការប្រោសមនុស្សមានជម្ងឺឱ្យជា នោះទ្រង់កំពុងតែធ្វើទៅតាមបំណងព្រះហឫទ័យ នៃព្រះវរបិតានោះ ។

ព្រះគម្ពីរម៉ាថាយ ៩:៣៥

**៣. ព្រះវិញ្ញាណបរិសុទ្ធ**

ការប្រោសឱ្យជាគឺជាការសំខាន់ ចំពោះព្រះវិញ្ញាណបរិសុទ្ធ និងជាផ្នែកមួយនៃគោលបំណងសម្រាប់ការចាក់ប្រេងតាំងរបស់ទ្រង់នោះឯង។ នៅក្នុងព្រះគម្ពីរលូកា យើងបានអានពីរបៀបដែល

ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បានចាក់ប្រេងតាំងដល់ព្រះយេស៊ូវ ក្នុងការប្រោសអ្នកមានចិត្តបាក់បែកនោះឱ្យជា ។

ព្រះគម្ពីរលូកា ៤:១៨

ទ្រង់បានចាក់ប្រេងតាំងឱ្យព្រះយេស៊ូវ ទ្រង់បានប្រោសដល់អស់អ្នកដែលទទួលការជិះជាន់ ដោយអារក្ស ។

ព្រះគម្ពីរកិច្ចការ ១០:៣៨

ការមានជម្ងឺរោគា គឺជាការទទួលនូវការកៀបសង្កត់មកពីអារក្សសាតាំងនោះឯង ។

## ខ. ការបញ្ជាក់ពីព្រះបន្ទូលរបស់ព្រះ

ការប្រោសឱ្យជាគឺជាការសំខាន់ ពីព្រោះវាគឺជាផ្លូវរបស់ព្រះអម្ចាស់ ក្នុងការបញ្ជាក់ពីព្រះបន្ទូលរបស់ទ្រង់ ដល់ពិភពលោកដែលបាត់បង់ និងមានភាពរឹងស្លួតនោះ ។

ព្រះគម្ពីរម៉ាកុស ១៦:២០

សព្វថ្ងៃនេះលោកិយត្រូវការព្រះយេស៊ូវ ។ ព្រះទ្រង់បានបញ្ជាឱ្យយើងចេញទៅគ្រប់ទិសទីកន្លែង ជាមួយនឹងទីសម្គាល់នៃការអស្ចារ្យ ដើម្បីបញ្ជាក់ពីព្រះបន្ទូលរបស់ព្រះអង្គនោះ ។ ការបណ្តេញពួកវិញ្ញាណអាក្រក់ និងប្រោសអ្នកជម្ងឺឱ្យជានឹងជួយបើកភ្នែកមនុស្សឱ្យបានឃើញនូវសេចក្តីពិត នៃដំណឹងល្អនោះឯង ។

## គ. តើព្រហយេស៊ូវទ្រង់បានរងទុក្ខជាអសាឥតការឬ?

ប្រសិនបើយើងមិនបានបំពេញការងារ ប្រោសអ្នកជម្ងឺឱ្យជាទេ នោះការរងទុក្ខទាំងប៉ុន្មាន ដែលព្រះយេស៊ូវទ្រង់បានចំណាយការរងទុក្ខនៃរូបកាយរបស់ព្រះអង្គ នោះត្រូវក្លាទៅជាអសាឥតការហើយ ។

ព្រះគម្ពីរអេសាយ ៥៣:៥

នៅពេលដែលយើងមិនអើពើដឹងនូវអ្វី ដែលព្រះបន្ទូលនៃព្រះបានចែងទុកមកអំពីការប្រោសឱ្យជា នោះគឺយើងកំពុងតែមិនអើពើដឹងនូវព្រះគុណនៃព្រះហើយ ។ យើងកំពុងតែធ្វើឱ្យការរងទុក្ខ ស្នាមជាំ ដែលព្រះយេស៊ូវទ្រង់ត្រូវបានបោះទម្លុះសម្រាប់ការប្រោសឱ្យជា នោះទៅជាគ្មានប្រសិទ្ធិភាពហើយ ។

ព្រះគម្ពីរកាឡាទី ២:២១

## ឃ. សូមឱ្យបានសង្គ្រោះដល់ជីវិតផង!

ការប្រោសឱ្យជាគឺអាចជួយសង្គ្រោះជីវិត របស់លោកអ្នកជីវិតរបស់គ្រុមគ្រួសារអ្នក និងមិត្តភក្តិរបស់លោកអ្នក ។ រីឯហោរាហូសេក៏បានសរសេរចែងទុកមកដែរ ។

ព្រះគម្ពីរហូសេ ៤:៦ក

ការប្រោសរូបកាយ និងព្រះលឹងរបស់លោកអ្នកឱ្យជានោះគឺជាការប្រទានអំណាច ដែលព្រះទ្រង់បានបង្កើតមកសម្រាប់យើងហើយ ។ យើងរាល់គ្នា ក៏ដូចជាស្តេចដាវីឌ គឺមិនត្រូវស្លាប់ទេ គឺនឹងត្រូវបានរស់នៅដ៏យូរអង្វែង និងមានសុខភាព រស់នៅធ្វើជាស្មរបន្ទាល់សម្រាប់ព្រះយេស៊ូវហើយ ។

ព្រះគម្ពីរទំនុកដំកើង ១១៨:១៧

ការបើកសម្តែងពីការប្រោសឱ្យជា ដែលនៅក្នុងព្រះបន្ទូលរបស់ព្រះ គឺបានរក្សាទុកជាច្រើនពីពួកអ្នកជំនាន់មុនដែលបានស្ទើរតែជិតផុតរលត់ទៅហើយនោះ ។

ព្រះគម្ពីរយ៉ាកុប៥:១៤-១៥

ចុះតើការអធិស្ឋាននៃសេចក្តីជំនឿ នឹងជួយសង្គ្រោះដល់អ្នកជម្ងឺនោះ ហើយព្រះអម្ចាស់ទ្រង់ក៏បានលើកគេឡើងដែរ ។ ចុះប្រសិនបើគេបានចុះចូលនឹងអំពើបាបវិញ នោះទ្រង់នឹងត្រូវអត់ទោសឱ្យគេហើយ ។

## ង. ចំណែកនៃមហាព្រះរាជបញ្ជា

### ១. ព្រះរាជបញ្ជាចុងក្រោយរបស់ព្រះយេស៊ូវ

ព្រះគម្ពីរម៉ាកុស ១៦:១៥-១៨

ព្រះបន្ទូលចុងក្រោយរបស់ព្រះយេ៊ូវ ទៅដល់ពួកអ្នកជឿ គឺមិនមែនជាការស្នើសុំទេ ។ វាគឺជាព្រះរាជបញ្ជា! រីឯការប្រោសអ្នកជម្ងឺឱ្យជាវិញ គឺជាការសំខាន់មួយ ប្រសិនបើយើងមានការស្តាប់បង្គាប់នោះ ។ ការប្រោសឱ្យជាផ្នែកដ៏សំខាន់មួយ នៃការហ្វឹកហ្វឺន និងការបំពេញការងារនៃពួកសិស្សរបស់ព្រះយេស៊ូវ និងពួកអ្នកដើរតាមព្រះអង្គ ។ គ្រាន់តែពេលដែលព្រះយេស៊ូវទ្រង់បានយាងចេញ ពីការប្រោសអ្នកជម្ងឺឱ្យជា នោះទ្រង់បានបញ្ជាពួកសិស្សទាំង១២នាក់ឱ្យធ្វើការដូច១គ្នា ។

ព្រះគម្ពីរម៉ាថាយ ១០:១,៧-៨

### ២. ព្រះរាជបញ្ជាចំពោះយើង

ការអធិស្ឋានដាក់ដៃលើអ្នកជម្ងឺ និងការបំពេញការងារប្រោសឱ្យជា គឺជាផ្នែកមួយនៃមហាព្រះរាជបញ្ជា ដែលព្រះយេស៊ូវទ្រង់បានប្រទាន មកពួកអ្នកជឿទាំងអស់ ។

ព្រះគម្ពីរយ៉ូហាន ១៤:១៥

ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា អ្នកណាដែលជឿដល់ទ្រង់ នោះនឹងធ្វើការដូចជាទ្រង់បានធ្វើដែរ ។ ការប្រោសឱ្យជា គឺត្រូវតែបានជាផ្នែកមួយដ៏សំខាន់ចំពោះយើង ប្រសិនបើយើងពិតជាបានធ្វើអ្វី ដែលព្រះយេស៊ូវទ្រង់បានធ្វើដែរ ។

ព្រះគម្ពីរយ៉ូហាន ១៤:១២

ព្រះយេស៊ូវទ្រង់បានមានព្រះបន្ទូលថា យើងនឹងបំពេញការងារប្រោសឱ្យជា ព្រមទាំងធ្វើការអស្ចារ្យដូចជាទ្រង់បានធ្វើដែរ ។ ព្រះយេស៊ូវទ្រង់បានចាត់ព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធ ឱ្យទ្រង់បានប្រទានអំណាចមកយើង ក្នុងការកាន់ខ្ជាប់តាមព្រះរាជបញ្ជារបស់ទ្រង់ ។

ព្រះគម្ពីរកិច្ចការ ១:៨

## III. ប្រភពនៃជម្ងឺរោគា

### ក. តើជម្ងឺរោគា ចេញមកពីព្រះ ឬមកពីសាតាំង?

អស់រយៈកាលជាយូរលង់មកហើយ ដែលមានការសង្ស័យខ្លះ១ទៅលើបញ្ហាទាំងនេះ គឺនៅក្នុងគំនិតរបស់យើង គឺនោះហើយដែលយើងនឹងបានជាគំនិតសង្ស័យទ្វេឡើង ដោយមានសេចក្តីជំនឿតែបន្តិចបន្តួចប៉ុណ្ណោះ សម្រាប់ការប្រោសឱ្យជានេះ ដែលនាំឱ្យជីវិតរស់នៅបានទទួលនូវការបរាជ័យ ។ ជាលំដាប់លំដោយទៅនេះ ហោរាក៏បានដឹងពីរបៀបដែលត្រូវទាក់ទងជាមួយនឹងបញ្ហានៃជម្ងឺរោគានេះ គឺយើងត្រូវតែមានការយល់ដឹងដ៏រឹងប៉ឹងអំពីភាពដើម ពីប្រភព និងគោលបំណងរបស់វា ។

### ខ.សេចក្ដីពិតនាំមកនូវសេរីភាព

នៅពេលដែលយើងរុករកឱ្យឃើញ នូវសេចក្ដីពិតរវាង ប្រភពនៃជម្ងឺរោគា ជម្ងឺ និងការឈឺចាប់ នោះយើងនឹងមាន ការជ្រើសរើដោយសេរី ដើម្បីឱ្យបានទទួលនូវការបំពេញការ ងារប្រោសឱ្យជាដោយអង់អាចនេះ ។ សេចក្ដីពិតគឺត្រូវបាន រកឃើញនៅក្នុងតួអង្គព្រះយេស៊ូវ ។

ព្រះគម្ពីរយ៉ូហាន ១៤:៦

សេចក្ដីពិតគឺត្រូវបានបើកសម្ដែងដោយព្រះបន្ទូល និង ព្រះរាចកិច្ចរបស់ព្រះយេស៊ូវ ។

ព្រះគម្ពីរយ៉ូហាន ៨:៣២

### គ. សំណួរចំពោះជម្ងឺរោគា

ដើម្បីរុករកឱ្យឃើញ នូវសេចក្ដីពិតអំពីភាពដើម ប្រភព និងគោលបំណងនៃជម្ងឺរោគានេះ គឺយើងត្រូវចាប់ផ្ដើមដោយ ការរកឃើញនូវចម្លើយទៅលើប្រភេទខ្លះៗ និងការសួរនូវ សំណួរជាញឹកញាប់ ។

**១. តើវាជាបំណងព្រះហឫទ័យរបស់ព្រះ ក្នុងការប្រោស ជម្ងឺឱ្យជាឬ?**

ចំពោះឧបស័គ្គដ៏ធំបំផុត ក្នុងការប្រោសជម្ងឺឱ្យ ជានេះ គឺមិនមែនជាបំណងព្រះហឫទ័យរបស់ផង ព្រះដ៏ពិតប្រាកដ ក្នុងការប្រោសគ្រប់គ្នាឱ្យបានជា នោះទេ ។ សាតាំងបានចូលមកប្រឆាំងនឹងយើង និង បានដាក់ពាក្យពេចនៃការសង្ស៊ែ មកក្នុងគំនិតរបស់ យើង គឺប្រសិនបើយើងមិនបានប្រុងប្រយ័ត្ន នោះ យើងនឹងដាក់ការសង្ស៊ែរនោះ ទៅដល់ការងារ ហើយ ។

យើងស្ដាប់ឮនូវការសង្ស៊ែរនេះ ដែលបានបញ្ជាក់ បង្ហាញ នៅក្នុងពាក្យសម្ដីនៃការអធិស្ឋាន ដូចជា ទំនៀមទម្លាប់ថា "ប្រសិនបើជាព្រះហឫទ័យរបស់ ទ្រង់ នោះយើងខ្ញុំទូលសូម ដល់ការប្រោសឱ្យជា របស់ទ្រង់ បានចូលមកប៉ះពាល់ ..."

ការអធិស្ឋានរបៀបនេះ គឺបញ្ជាក់បង្ហាញពីការ មិនពិតប្រាកដ និងការសង្ស៊ែរអំពីថា តើវាជាបំណង ព្រះហឫទ័យរបស់ព្រះ ក្នុងការប្រោសឱ្យជាទៅវិញ វាគឺជាការគ្មានលទ្ធភាពក្នុងការអធិស្ឋាន ដែលជា សេចក្ដីអធិស្ឋាននៃជំនឿដោយខ្លួនយើង និងសម្រាប់ អ្នកដទៃឬក៏អត់តែប៉ុណ្ណោះ ។

យើងមើលឃើញនូវការបើកសម្ដែង ពីការ សង្ស៊ែររបៀបនេះ នៅក្នុងមនុស្សកើតរោគឃ្លង់ គឺ នៅពេលដែលគាត់បាននិយាយថា "ប្រសិនបើទ្រង់ សព្វព្រះហឫទ័យ" នោះតែប៉ុណ្ណោះ ។

ព្រះគម្ពីរម៉ាកុស ១:៣៩-៤១

ព្រះយេស៊ូវទ្រង់បានដកចេញ នូវពាក្យ "ប្រសិន បើ" ដោយទ្រង់មានព្រះបន្ទូលជាប្រយោគធម្មតា វិញថា "ខ្ញុំចង់ដែរ" ។ គ្រប់ដែលព្រះយេស៊ូវទ្រង់បាន ធ្វើ គឺជាការបើកសម្ដែង ពីបំណងព្រះហឫទ័យនៃ ព្រះវរបិតាសម្រាប់ពួកប្រជារាស្ត្ររបស់ព្រះអង្គ ។

**២. តើជម្ងឺរោគាគឺជាមធ្យោបាយមួយ ដែលព្រះទ្រង់ធ្វើ ការរួមគ្នាជាមួយនឹងសេចក្ដីល្អរបស់យើងឬ?**

មានមនុស្សជាច្រើនបានបង្រៀនថា ជម្ងឺរោគា គឺជាការមួយទៅលើ "គ្រប់ការទាំងអស់" ដែល លោកសាវ័ក ប៉ុលបានមានប្រសាសន៍ថា ត្រូវតែធ្វើ

ការរួមគ្នាសម្រាប់ជាសេចក្ដីល្អ ។ ព្រះគម្ពីររ៉ូម ៨:២៨ ។

នៅក្នុងព្រះគម្ពីរ អិនអាយវី ផ្ដល់ឱ្យយើងពីការយល់ដឹងច្បាស់លាស់ទៅលើព្រះបន្ទូល ។ គឺបានថែងមកយ៉ាងដូច្នេះថាៈ យើងដឹងថា គ្រប់ការទាំងអស់ដែលព្រះទ្រង់ធ្វើ គឺសម្រាប់ជាសេចក្ដីល្អដល់អស់អ្នកដែលស្រឡាញ់ទ្រង់ គឺជាអស់អ្នកដែលបានហៅមកតាមព្រះតម្រិះទ្រង់ ។

ចំពោះការគូសបញ្ជាក់គឺពាក្យ "នៅក្នុង" គ្រប់ទាំងអស់ដែលព្រះទ្រង់ធ្វើការ គឺសម្រាប់ជាសេចក្ដីល្អរបស់យើង ។ វាមិនមែនជាការថែងមកថា គ្រប់ការដែលធ្វើរួមគ្នាទាំងអស់ គឺសម្រាប់ជាសេចក្ដីល្អរបស់យើងនោះទេ ។ ជំនួសឱ្យនូវពាក្យ "ក្នុងគ្រប់ទាំងអស់" ឬ "ក្នុងជម្ងឺរោគារបស់យើង" នេះគឺសម្រាប់ការងារ ដែលមានអំណាចចេស្ដានៃការប្រោសឱ្យជារបស់ព្រះ នឹងបានជាការផលិតដ៏ល្អនោះឯង ។

### ៣. វាគឺជាបំណងព្រះហឫទ័យរបស់ព្រះដល់ខ្ញុំ ឱ្យទៅជាមានជម្ងឺឬអី?

វាគឺជាបំណងព្រះហឫទ័យរបស់ព្រះ សម្រាប់គ្រប់ការទាំងអស់នៅខាងលើ ដែលយើងរស់នៅក្នុងសុខភាពល្អជារៀងរាល់ថ្ងៃ ។

ព្រះគម្ពីរ ៣យ៉ូហាន ខ.២

ប្រសិនបើព្រះយេស៊ូវ ទ្រង់បានប្រោសជម្ងឺឱ្យជានោះគឺជាបំណងព្រះហឫទ័យនៃព្រះវរបិតា ក្នុងការប្រោសអ្នកជម្ងឺនោះឱ្យជាហើយ ។ ចាប់តាំងពីបំណងព្រះហឫទ័យនៃព្រះវរបិតា ក្នុងការប្រោសអ្នកជម្ងឺឱ្យជា នោះក៏ជាបំណងព្រះហឫទ័យនៃព្រះវរបិតាក្នុងការប្រោសលោកអ្នកឱ្យជានោះដែរ!

### ៤. តើជម្ងឺរោគាគឺជាមធ្យោបាយមួយ ដែលយើងត្រូវតែរងទុក្ខសម្រាប់ព្រះអង្គឬ?

ព្រះគម្ពីរអេភេសូរ ១:២៩

ត្រូវតែជៀសវាង ក្នុងការបកស្រាយព្រះបន្ទូលខុស វាគឺជាការចាំបាច់ក្នុងការប្រឹក្សាពីអត្ថបទ ឬការជ្រើសរើសអត្ថបទនៃប្រធានបទនីមួយៗ ។ នៅក្នុងស្ថានការណ៍នេះ លោកសាវ័កប៉ុល បាននៅក្នុងគុកគឺគាត់បានសរសេរអំពីការរងទុក្ខរបស់គាត់ ដោយជាប់ច្រវាក់ ដោយសារដំណឹងល្អ ។

ព្រះគម្ពីរភីលីព ១:១២-១៤

វាគឺជាការជាក់ស្ដែង ពីបរិបទនៃព្រះរាជសារដែលបាននិយាយពីការរងទុក្ខ គឺដែលលោកសាវ័កប៉ុលបាននិយាយអំពីជម្ងឺ និងជម្ងឺរោគាដែលគ្មានខយោងបញ្ជាក់នោះ ។ ជំនួសឱ្យនូវការនេះ វាគឺជាការរងទុក្ខដោយការបៀតបៀន និងការជាប់គុកនោះ គឺសម្រាប់ជាបុព្វហេតុនៃដំណឹងល្អនោះឯង ។

### ៥. តើវាគឺជាការដាក់ពិន័យឬ?

តើព្រះទ្រង់ដាក់ជម្ងឺទៅលើបណ្ដាជន ដើម្បីកែថ្មែ ឬដាក់ពិន័យ ឬធ្វើទារុណកម្មឬ ឬក៏ជាការបង្រៀនពួកគេ ឱ្យចេះទ្រាំទ្រអត់ធ្មត់?

សាតាំងមិនមែនជាព្រះទេ វាគឺជាម្នាក់ដែលដាក់ជម្ងឺ និងជម្ងឺរោគាមកលើមនុស្ស ។

ព្រះគម្ពីរយ៉ូប ២:៧

យើងមិនត្រូវមានរូបភាពសេចក្តីស្រឡាញ់ ការនាំមកនូវ ឪពុកជាមនុស្សក្នុងការបន្តជម្ងឺមហារីកទៅលើកូនចៅ ក្នុងការដាក់ទណ្ឌកម្មដល់ពួកគេនោះទេ ។ តើយើងអាចដាក់រូបភាពព្រះវរបិតានៃយើង ដែលគង់នៅនៅស្ថានសួគ៌ ក្នុងការដាក់ជម្ងឺ ឬជម្ងឺរោគាទៅលើកូនរបស់ផងទ្រង់បានដោយរបៀបណា?

ព្រះគម្ពីរយ៉ូហាន ១០:១០

ព្រះយេស៊ូវទ្រង់មានបន្ទូលថា វាគឺជាវិញ្ញាណអាក្រក់ ដែលចូលមកស្លាប់យើង ដោយការលួចនូវសុខភាពរបស់យើង និងបំផ្លាញយើងដោយជម្ងឺ និងជម្ងឺរោគានោះឯង ។ ប៉ុន្តែ ព្រះយេស៊ូវទ្រង់បានយាងមក ដើម្បីប្រទានជីវិតដល់យើង គឺឱ្យយើងមានជីវិតពេញបរិបូរ ដោយគ្មានជម្ងឺ ជម្ងឺរោគា និងគ្មានការឈឺចុកចាប់នោះឯង ។ ទ្រង់បានយាងមកកែយើងទាំងអស់គ្នា គឺដែលទ្រង់បានបង្កើតមនុស្សជាតិមកឱ្យមាននៅ នៅពេលដែលទ្រង់បានបង្កើតលោកអ័ដាម និងនាងអេវ៉ាមក ឱ្យមានរូបភាពដូចជាព្រះអង្គនោះឯង ។

## ៦. តើបន្លារបស់លោកសាវ័កប៉ុល គឺចង់និយាយពីអ្វី?

តើព្រះគម្ពីរនិយាយថា បន្លារបស់លោកប៉ុល គឺជាជម្ងឺឬ?

តាមរយៈការមិនយល់ពីព្រះបន្ទូល គឺមានអ្នកខ្លះបានបង្រៀនថា បន្លារបស់លោកសាវ័កប៉ុល ដែលចាក់ទៅក្នុងសាច់ឈាម គឺជាជម្ងឺដែលមានភ្នែកដ៏ធ្ងន់នោះឯង ។ ទោះជាយ៉ាងណាក៏ដោយ លោកសាវ័កប៉ុលបានសរសេរថា បន្លារបស់គាត់ គឺជាវិញ្ញាណអាក្រក់ ជាសាររបស់សាតាំង ដែលបានបញ្ជូនមកឱ្យចាក់រុក ឬរំខានដល់គាត់ ។

ព្រះគម្ពីរ ២កូរិនថូស ១២:៧

ចុះឥឡូវនេះវិញ តើព្រះគម្ពីរបានបង្រៀនថា បន្លាដែលនៅក្នុងសាច់ឈាមរបស់លោកប៉ុល គឺជាជម្ងឺខាងរូបកាយឬ?

## ៧. តើត្រូវការនាំមកនូវសេចក្តីស្លាប់ឬ?

នៅពេលដែលព្រះទ្រង់បានដាក់យើង ឱ្យបានទៅជាផ្ទះរបស់ទ្រង់ហើយនោះ តើយើងត្រូវការទទួលនូវជម្ងឺ ឱ្យត្រូវស្លាប់ឬទេ?

ប្រសិនបើជាបំណងព្រះហឬទ័យរបស់ព្រះ ដែលយើងរស់នៅឱ្យមានសុខភាពជារៀងរាល់ថ្ងៃ នៅក្នុងជីវិតរបស់យើង ហេតុអ្វីបានជាទ្រង់បង្កើតជម្ងឺជាការចាំបាច់ ដែលយើងត្រូវតែមានជម្ងឺឱ្យត្រូវស្លាប់ធ្វើអី? លោកម៉ូសេគឺជាអ្នកគំរូដ៏អស្ចារ្យម្នាក់! គឺជាម្នាក់ដែលមានអាយុ១២០ឆ្នាំ គឺនៅពេលដែលព្រះទ្រង់បានត្រាស់ហៅគាត់ ឱ្យបានមកជាផ្ទះរបស់ទ្រង់នោះឯង ។ រីឯសុខភាពរបស់គាត់ គឺល្អខ្លាំងណាស់ គាត់នៅតែមានលទ្ធភាពឡើងលើភ្នំ ទៅជួបនឹងព្រះ ។ គាត់មិនដែលមានការបាត់បង់នូវការមើលឃើញ ឬក៏មានការបាត់បង់កម្លាំង ខាងឯធម្មជាតិរបស់គាត់នោះឡើយ ។

ព្រះគម្ពីរចោទិយកថា ៣៤:៧

មនុស្សនៅពេលដែលចាស់ទៅ គឺត្រូវតែមានជម្ងឺ វាគឺជាបំណងព្រះហឬទ័យរបស់ព្រះ សម្រាប់ពួកគេ ក្នុងការទទួលនូវការប្រោសឱ្យជា ។ វាគឺជា

ពេលវេលារបស់ព្រះ ដែលវិញ្ញាណរបស់ពួកគេ នឹងចាកចេញពីរូបកាយរបស់ពួកគេទៅនោះ ហើយចិត្តរបស់ពួកគេនឹងឈប់មានការល្ងើងជូរចត់តទៅទៀត។

ព្រះគម្ពីរទំនុកដំកើង ១០៥:៣៧

## ៨. តើទ្រង់បានអនុញ្ញាតឱ្យការនោះកើងឡើងឬ?

តើព្រះទ្រង់"បានអនុញ្ញាត" ឱ្យជម្ងឺ ឬក៏ជាការស្លាប់មុនកំណត់បានចូលមកដោយនិយាយថា "ហេតុអ្វីបានជាព្រះទ្រង់បានអនុញ្ញាត ឱ្យការនេះកើតឡើង?"

លោកអ័ដាម និងនាងអេវ៉ា គឺត្រូវបានប្រទានឱ្យនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងលើគ្រប់ទាំងអស់ ដែលបានកើតឡើងនៅលើផែនដីនេះ គឺពេលដែលពួកគេត្រូវបានបង្កើតមក ឱ្យមានរូបភាពរបស់ព្រះ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៦ក

សិទ្ធិអំណាច ឬអំណាចគ្រប់គ្រង ដែលបានបាត់បង់ទៅ នោះគឺនៅពេលដែលលោកអ័ដាម និងនាងអេវ៉ាបានធ្វើបាប នោះក៏ត្រូវបានកែជាថ្មីដោយព្រះយេស៊ូវ ។

ព្រះគម្ពីរម៉ាថាយ ១៦:១៩

ជម្ងឺបានចូលមក តាមរយៈអំណាចរបស់សាតាំង ប៉ុន្តែ ព្រះយេស៊ូវទ្រង់មានបន្ទូលថា ថ្ងៃនេះពួកអ្នកជឿមានអំណាច (ឬសិទ្ធិអំណាច) គ្រប់គ្រងលើអំណាចរបស់ខ្មាំងសត្រូវឡើងវិញហើយ ។

ព្រះគម្ពីរលូកា ១០:១៩

ដោយការមិនប្រើនូវអំណាចគ្រប់គ្រង ដែលព្រះទ្រង់បាន ប្រទានពរមកហើយនៅលើផែនដីនេះ នោះយើងនៅ ក្នុងការមិនអើពើដឹងរបស់យើង គឺមិនមែនជាការអើ ពើដឹងរបស់ព្រះនោះទេ គឺយើងបានអនុញ្ញាតឱ្យទៅសាតាំង នាំយកនូវជម្ងឺ ជម្ងឺរោគា និងសេចក្តីស្លាប់ដោយខ្លួនយើង និងអ្នកជាទីស្រឡាញ់របស់យើង ។

## ៩. ប្រភពនៃជម្ងឺ

គ្រប់ទាំងជម្ងឺ និងជម្ងឺរោគា គឺបានមកពីអារក្សសាតាំង មិនមែនបានមកពីព្រះទេ ។ មានមនុស្សជាច្រើនមានជម្ងឺ គឺដោយសារតែពួកគេបានទទួលនូវកន្លែង ដែលជាវិញ្ញាណពិការភាព តាមរយៈអំពើបាប ការមិនស្តាប់បង្គាប់ ឬក៏តាមការមិនអើពើដឹងពីគោលការណ៍នៃសុខភាពល្អ និងភាពធាត់ធំនោះឯង ។

ព្រះគម្ពីរអេភេសូរ ៤:២៧

ការប្រើនូវសិទ្ធិអំណាច ដែលបានកែជាថ្មីរបស់យើង នោះយើងអាចទប់ទល់ជាមួយនឹងវិញ្ញាណអាក្រក់ ពពួកវិញ្ញាណពិការភាព ឬក៏ជាមួយនឹងជម្ងឺដែលបានចូលមក ហើយពួកវានឹងត្រូវរត់ចេញពីយើងទៅ ។

ព្រះគម្ពីរយ៉ាកុប ៤:៧ខ

ពួកអ្នកជឿមានសិទ្ធិអំណាច ដើម្បីដេញវិញ្ញាណពិការភាព និងប្រោសអ្នកជម្ងឺ និងជម្ងឺរោគាគ្រប់ប្រភេទនោះឱ្យបានជា ។

ព្រះគម្ពីរម៉ាថាយ ១០:១

មានតែរឿងមួយទេ ដែលសាតាំងអាចធ្វើបាន នៅសម័យសព្វថ្ងៃនេះ គឺជាអ្វីដែលយើងបាន អនុញ្ញាតឱ្យវាធ្វើ ។ សំណួរគឺមិនត្រូវបានយ៉ាងដូច្នេះឡើយគឺ "ហេតុអ្វីបានជាព្រះទ្រង់បានអនុញ្ញាតឱ្យ ការនេះកើតឡើង យ៉ាងដូច្នេះ?"

កំណត់ចំណាំៈ ដើម្បីឱ្យយល់នូវសំណួរនេះបាន ពេញលេញ នោះយើងត្រូវតែផ្តល់សំណូមពរ ឱ្យ លោកអ្នកបានអានសៀវភៅ **សិទ្ធិអំណាចរបស់អ្នកជឿ** ដែលនិពន្ធ ដោយលោក **អេ.អែល. ហ្គីល** និងសៀវភៅ **ការឆ្ពោះទៅរកជោគជ័យសម្រាប់អំណាចគ្រប់គ្រង** ។

## IV. សាតាំងបានប្រើថម្ងឺធ្វើជាអាវុធដើម្បីផ្តួលយើង ។

### ក. ការធ្លាក់ចុះរបស់សាតាំង

សាតាំងនិងពួកទេវតារបស់វា គឺត្រូវបានបណ្តេញចុះមកផែនដី បន្ទាប់ពីការទាស់ទទឹងរបស់ពួកវានៅឯនគរស្ថានសួគ៌នោះ ។ យើងបានអានដោយមានការទទួលខុសត្រូវ ។

ព្រះគម្ពីរវិវរណៈ១២:៧-១០

### ខ. មនុស្សដែលនៅក្នុងរូបភាពរបស់ព្រះ

ព្រះទ្រង់បានបង្កើតជាតិមក ឱ្យមានរូបភាពរបស់ព្រះអង្គនៅលើភពផែនដី ដែលសាតាំងត្រូវបានបណ្តេញមកឱ្យនៅនោះឯង ។ ទ្រង់បានបង្កើតពួកគេមកឱ្យមានអំណាចគ្រប់គ្រងលើផែនដី ដែលរួមទាំងសាតាំងផងដែរ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៦-២៨

មនុស្សជាតិត្រូវបានបង្កើតមកគឺដើម្បីៈ

**១. មានរូបដូចជាព្រះ**

**២. ដើរដូចជាព្រះ**

**៣. និយាយដូចជាព្រះ**

**៤. និងមានអំណាចគ្រប់គ្រងលើផែនដីនេះ!**

### គ. សាតាំងស្អប់លោកអ្នក ។

ចូរធ្វើការស្រមើស្រមៃ ទៅឯកន្លែងរបស់សាតាំង ។ ចាប់តាំងពីតួនាទីដ៏ខ្ពស់បំផុតនៅឯនគរស្ថានសួគ៌មក វាក៏ត្រូវបានទទួលនូវការបណ្តេញចេញមកកាន់ភពផែនដី ។ វាក៏បានធ្វើការលេងដែលគួរឱ្យស្អប់ ដោយការទាស់ទទឹងជាមួយនឹងព្រះ ដែលវាគឺជាម្នាក់ដែលចង់ធំស្មើព្រះដ៏ខ្ពស់បំផុតនោះ គឺវាត្រូវតែចាំឃ្លាំមើលដោយភ័យខ្លាច ដូចជាព្រះទ្រង់បានបង្កើតមនុស្សជាតិ ឱ្យមានរូបដូចអង្គទ្រង់។ ហើយបន្ទាប់មកទៀតព្រះទ្រង់ក៏បានប្រទានអំណាចគ្រប់គ្រងដល់ពួកគេ ដែលវាកំពុងតែបានគ្រប់គ្រងលើផែនដីនេះ!

គ្រប់ពេលដែលសាតាំងបានឃើញមនុស្សប្រុសស្រី នោះវាក៏បានចងចាំដល់ព្រះ ដែលទ្រង់កំពុងតែមានសេចក្តីក្រោធដ៏ធំបំផុតចំពោះវានោះ ។ នៅពេលដែលវាបានមើលឃើញមនុស្សជាតិ ដែលមានរូបភាពដូចជាព្រះ និងមានសកម្មភាពដូចជាព្រះ នោះសេចក្តីកំហឹងរបស់វាគឺត្រូវពុះកញ្ជ្រោលយ៉ាងខ្លាំង ។ ការចង្អុលបង្ហាញពីសេចក្តីកំហឹងនោះ គឺវាត្រូវតែលួចសម្លាប់ និងបំផ្លាញនោះឯង ។

លោកសាវ័កយ៉ូហានក៏បានសរសេរចែងទុកមក ។

ព្រះគម្ពីរយ៉ូហាន ១០:១០ក

សាតាំងដឹងថា យើងគឺជាអ្នកតំណាងឱ្យព្រះនៅលើផែនដីនេះ ។ យើងគឺជារូបកាយរបស់ព្រះគ្រីស្ទ និងជាអ្នកសម្រេចចិត្តដ៏ធំបំផុតរបស់វា ដែលវាត្រូវតែធ្វើឱ្យយើងត្រូវបរាជ័យ ។

ការបាត់បង់ ការស្លាប់ និងការបំផ្លាញ គឺជាការងាររបស់សាតាំងហើយ ។ អស់រយៈកាលបួនពាន់ឆ្នាំក្រោយពូការធ្លាក់ចុះរបស់លោកអ័ដាម និងនាងអេវ៉ាមក នោះមនុស្សជាតិបានរស់នៅក្រោមការជាប់ទោស ការជាប់ចំណង និងការសង្កត់សង្កិនរបស់វិញ្ញាណអាក្រក់ ។

មនុស្សជាតិដែលរស់នៅ គឺដែលត្រូវបានបង្កើតមកឱ្យបានដើរដោយអំណាចគ្រប់គ្រង គឺត្រូវបានទៅជាមនុស្សពិការ និងមនុស្សខ្វាក់ ដែលអង្គុយនៅតាមផ្លូវសុំទាននោះវិញ ។

ស្ត្រីម្នាក់ដែលត្រូវបានបង្កើតមក ឱ្យបានដើរដោយមានភាពត្រឹមត្រូវ គឺត្រូវបានទៅជាមនុស្សពិការ និងត្រូវក្រាបចុះនៅក្នុងការឈឺចាប់ និងការអស់សង្ឃឹម ។

មនុស្សប្រុសស្រីដែលត្រូវបានបង្កើតមក ឱ្យបានដូចជាព្រះ (នៅក្នុងរូបរបស់ព្រះអង្គ) ដែលឥឡូវនេះត្រូវបានទទួលនូវការត្រឡប់ទៅជាមនុស្សសំខាន់ នៅចំពោះមុខនិងរូបកាយរបស់ពួកគេ ត្រូវបានបោះទៅខាងក្រៅឱ្យបានស៊ីផឹកជាមួយនឹងមនុស្សកើតរោគឃ្លង់វិញ ។

## ឃ. ព្រះយេស៊ូវទ្រង់មានផែនការដ៏ល្អប្រសើរ សម្រាប់យើងរាល់គ្នា ។

ព្រះយេស៊ូវទ្រង់បានយាងមកជ្រើសរើសមនុស្សជាតិ ឱ្យមានសេរីរួចខ្លួនពីការជាប់ទោស ការជាប់ចំណង និងពីការកៀបសង្កត់របស់ជម្ងឺ ជម្ងឺរោគា និងការឈឺចាប់ជាដើម ។

ព្រះទ្រង់សព្វព្រះហឫទ័យឱ្យយើង បានរួចខ្លួនពីការកៀបសង្កត់របស់សាតាំង ។ ទ្រង់សព្វព្រះហឫទ័យចង់ឱ្យយើងត្រូវរំដោះរួចពីការជាប់ចំណងនៃអំពើបាប ។ ព្រះទ្រង់សព្វព្រះហឫទ័យឱ្យយើងបានស្រួលខ្លួន!

*ប្រភពនៃជម្ងឺនិងជម្ងឺរោគាគឺជាសាតាំង គឺមិនមែនជាព្រះទេ!*

# ក្រុមពិភាក្សា

១. ព្រះយេស៊ូវទ្រង់មានសេចក្តីមេត្តាករុណា ចំពោះអ្នកជម្ងឺ ។ ចូរចែកចាយពីសាច់រឿងទាំងពីរ ចេញពីក្នុងព្រះគម្ពីរ ដែលព្រះយេស៊ូវទ្រង់បានរើចេញ ដោយមានសេចក្តីមេត្តាករុណា និងការប្រោសអ្នកជម្ងឺឱ្យជា ។

២. តើអ្នកណាបានដាក់ជម្ងឺទៅលើមនុស្ស ចុះតើហេតុអ្វី?

៣. ចូរពិភាក្សាបន្ថែមឱ្យកាន់តែជ្រៅជាងនេះ នូវការដាក់ប្រយោគជាបន្តបន្ទាប់ៈ "ត្រូវតែដឹងឱ្យបានសមរម្យជាលំដាប់លំដោយ នូវរបៀបទាក់ទងជាមួយនឹងបញ្ហានៃជម្ងឺ ដែលយើងត្រូវតែមានការយល់ដឹងដ៏រឹងមាំ ពីភាពដើមរបស់វាពីប្រភពរបស់វា និងពីគោលបំណងរបស់វា" ។

# ការសិក្សាដោយខ្លួនឯង

១. ការភ័យខ្លាចដ៏ធំបំផុតចំពោះការប្រោសឱ្យជា គឺមិនពិតប្រាកដចំពោះបំណងព្រះហឫទ័យរបស់ព្រះ ដើម្បីប្រោសគ្រប់គ្នាឱ្យបានជានោះទេ ។ តើលោកអ្នកអាចធ្វើយ៉ាងដូចម្តេច ដើម្បីធ្វើឱ្យបានពិតប្រាកដ រីឯលោកអ្នកវិញគឺមានការពិតនៅក្នុងវិញ្ញាណរបស់លោកអ្នក ដែលវាគឺជាបំណងព្រះហឫទ័យរបស់ព្រះ ក្នុងការប្រោសឱ្យជានោះឬ?

២. យើងគឺជាតំណាងរបស់ព្រះនៅលើផែនដីនេះ ។ ចូរចងចាំថា វាគឺជាបំណងប្រាថ្នាដ៏ធំបំផុតរបស់សាតាំង គឺឱ្យយើងត្រូវចុះចាញ់ គឺដោយព្រោះតែវាដឹងថា យើងគឺជាតំណាងរបស់ព្រះ ។ តើលោកអ្នកត្រូវធ្វើអ្វីដើម្បីដើរដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងបន្ថែមទៀត ដែលព្រះទ្រង់បានបង្កើតលោកអ្នកឱ្យមាននោះ?

៣. ព្រះយេស៊ូវទ្រង់សព្វព្រះហឫទ័យប្រោសឱ្យជា ។ ទ្រង់បានបដិសេធចំពោះពាក្យ "ប្រសិនបើ" ដោយមានបន្ទូលថា "ខ្ញុំចង់ដែរ" ។ សូមឱ្យខនេះបានស្រូបចូលទៅក្នុងវិញ្ញាណរបស់លោកអ្នក ។ ចូរចងចាំថា នៅពេលដែលលោកអ្នកអធិស្ឋានសម្រាប់ការប្រោសឱ្យជា ដល់អ្នកណាម្នាក់នោះ ។ ចូរអធិស្ឋានដោយពិតប្រាកដ នោះគឺជាបំណងព្រះហឫទ័យរបស់ព្រះ ក្នុងការប្រោសឱ្យជាហើយ ។

# ការប្រទានអំណាចរបស់ព្រះ សម្រាប់ការប្រោសឱ្យជា

## *មេរៀនទី ២: ព្រះយេស៊ូវ ទ្រង់គឺជាអ្នកប្រោសឱ្យជារបស់យើង*

### I. ការសម្រេចព្រះទ័យរបស់ព្រះ

ព្រះគម្ពីរ ៣យ៉ូហាន ខ.២

ព្រះគម្ពីរទំនុកដំកើង ១០៧:២០

ព្រះគម្ពីរអេសាយ ៥៥:១១

### ក. សេចក្តីអធិស្ឋានរបស់លោកសាវ័កប៉ុល

នៅក្នុងព្រះគម្ពីរអេភេសូរ ២:១៦-១៧

យើងក៏ត្រូវការអធិស្ឋានជាសេចក្តីអធិស្ឋាន សម្រាប់ខ្លួនយើង និងសម្រាប់អ្នកដទៃទៀតនៅថ្ងៃនេះផងដែរ ។ អ្វីដែលយើងអាចស្គាល់ដល់ព្រះបាន គឺដោយនូវភាពពេញលេញរបស់ទ្រង់ ដែលរួមបញ្ចូលទាំងការស្គាល់ទ្រង់ ជាយេហូវ៉ារ៉ាហ្វា គឺជាអម្ចាស់ដ៏ជាអ្នកប្រោសឱ្យជារបស់យើងនោះឯង ។

ព្រះគម្ពីរនិក្ខមនំ ១៥:២៦

### ខ. ការស្គាល់ព្រះដ៏ជាអ្នកប្រោសឱ្យជារបស់អ្នក

ព្រះគម្ពីរដានីយ៉ែល ១១:៣២

ការដើរដោយព្រះវិញ្ញាណនៃប្រាជ្ញា គឺមានន័យថា យើងនឹងស្គាល់ព្រះ ដើរដូចជាព្រះ សំដៅទៅឯពេលវេលារបស់ទ្រង់នោះឯង ។

ព្រះវិញ្ញាណនៃការបើកសម្តែង គឺអាចយាងមកនៅពេលដែលយើងអានព្រះគម្ពីរ ហើយក្នុងមួយរំពេចនោះឯង ខគម្ពីរក៏នឹងបានត្រឡប់ជាមានជីវិតរស់ ហើយនិយាយដោយអំណាចទៅចំពោះស្ថានការណ៍ ដែលយើងបានរកឃើញដោយខ្លួនឯងនោះ ។ នោះគឺជាការទទួលពាក្យ រេម៉ា ។ សេចក្តីជំនឿ បានចាប់យកការគាំទ្រពីព្រះបន្ទូលនោះ ដូចជាប្រសិនបើខគម្ពីរដែលទើបតែនឹងលេចឡើង នៅក្នុងព្រះគម្ពីរនោះគឺសម្រាប់យើងហើយ ។

ព្រះគម្ពីររ៉ូម ១០:១៧

ខ្ញុំបានស្គាល់ព្រះយេស៊ូវ ទ្រង់ជាព្រះអង្គសង្គ្រោះរបស់ខ្ញុំ ។ ជាច្រើនឆ្នាំកន្លងផុតមក ដែលខ្ញុំបានចូលមកស្គាល់ព្រះយេស៊ូវជាអ្នកប្រោសលោះរបស់ខ្ញុំ គឺជាយេហូវ៉ារ៉ាហ្វា ហើយខ្ញុំក៏បានដើរដោយមានសុខភាពនៅថ្ងៃនេះ ។

### II. ប្រភេទនៃព្រះគម្ពីរសញ្ញាចាស់

លោកអ័ប្រាហាំ អ៊ីសាក និងយ៉ាកុបបានស្គាល់ព្រះ ។ លោកអ័ប្រាហាំគឺជាមិត្តភក្តិរបស់ព្រះ ។ អស់រយៈកាលរាប់រយឆ្នាំក្រោយមក គឺដោយសារតែអំពើបាប នោះពួកកូនចៅរបស់អ្នកទាំងបីនាក់នេះ បានត្រឡប់ទៅជាទាសករនៅស្រុកអេស៊ីព្ទ ។ នេះគឺជារូបភាពរបស់លោកអ្នក ហើយនិងខ្ញុំ ។ បន្ទាប់ពីយើងបានជួបព្រះយេស៊ូវ ធ្វើជាព្រះអង្គសង្គ្រោះរបស់យើង នោះយើងមិនត្រូវការធ្វើជាទាសករតទៅទៀតឡើយ ។ ដែលជាចម្លើយ គឺធ្វើឱ្យព្រះលោហិតបានបំផ្លាស់បំប្រែគ្រប់បែបយ៉ាង ។

### ក. ការត្រាស់ហៅនិងការស្ដាប់បង្គាប់របស់លោកម៉ូសេ

នៅក្នុងព្រះគម្ពីរនិក្ខមនំជំពូកទី៣ ព្រះទ្រង់បានមានព្រះបន្ទូលពីក្នុងគម្ពបន្លាដែលភ្លើងកំពុងតែឆេះ គឺជាព្រះរាជបញ្ជាដល់លោកម៉ូសេ ឱ្យទៅកាន់ស្រុកអេស៊ីព្ទ និងជួយរំដោះពួកបណ្ដាជនឱ្យមានសេរីភាពឡើងវិញ ។ មានការអស្ចារ្យ និងឧបទ្រព្យចង្រៃឡើងដល់កម្រិតខ្ពស់ នៅក្នុងពិធីបុណ្យរំលងលើកទីមួយនៅក្នុងព្រះគម្ពីរនិក្ខមនំជំពូកទី១២ ។ នេះគឺជារូបមន្តដែលព្រះយេស៊ូវទ្រង់ដ៏ជាព្រះគ្រីស្ទ គឺទ្រង់បានសុគតជំនួសលោកិយទាំងមូល ។ ពេលដែលយើងបានទទួលនូវចម្លើយគឺជាព្រះលោហិតរបស់ព្រះយេស៊ូវ ដែលយើងក៏ត្រូវបានដោះឱ្យរួចដែរ ។ (វាគឺជាពេលសម្រាប់យើងក្នុងការដោះចេញនូវចំណងនៃស្រុកអេស៊ីព្ទនោះ) ។ នៅពេលដែលពួកគេបានចាកចេញពីស្រុកអេស៊ីព្ទ នោះពួកគេបានប្រឈមមុខទៅនឹងស្ថានភាពដែលគ្មានលទ្ធភាព នៅឯសមុទ្រក្រហមនោះ ។ ព្រះទ្រង់បានបញ្ជាឱ្យពួកកូនចៅអ៊ីស្រាអែល បានឈរឱ្យ មាំមួន ។

ព្រះគម្ពីរនិក្ខមនំ ១៤:១៣

លោកម៉ូសេក៏បានវាយដំបងរបស់គាត់ ហើយពួកកូនចៅអ៊ីស្រាអែលក៏ដើរលើដីគោក ។ ពាក្យ "សេចក្ដីសង្គ្រោះ" គឺរួមបញ្ចូលទាំងការប្រោសឱ្យជា ទាំងការរំដោះ និងទាំងការដោះឱ្យមានសេរីរួចពីចំណងផង ។

នេះគឺជាពេលសម្រាប់ពួកគ្រីស្ទាន ដើម្បីឱ្យបានដោះចេញពីចំណងនៃជម្ងឺ និងជម្ងឺរោគានេះឯង ។ ចូរឈរឱ្យបានមាំមួនរហើយនិងមើលឱ្យឃើញ នូវសេចក្ដីសង្គ្រោះរបស់ព្រះអម្ចាស់។ សេចក្ដីសង្គ្រោះគឺប្រសើរជាជាងរកមធ្យោបាយមួយ ដើម្បីជាការទិញសំបុត្រទៅស្ថានសួគ៌ ។ សេចក្ដីសង្គ្រោះគឺជាការកែយើងជាថ្មីឡើងវិញ គឺឱ្យបានជាតួនាទីដែលព្រះទ្រង់បានបម្រុងទុកសម្រាប់យើងឱ្យមានការពិសោធន៍ ។

ប៉ុន្តែ ពួកអ្នកស្រុកអេស៊ីព្ទក៏បានពួកគេចូលទៅក្នុងសមុទ្រនោះដែរ ។ លោកម៉ូសេក៏បានវាយដំបងរបស់គាត់ម្ដងទៀត ហើយពួកខ្មាំងសត្រូវក៏ត្រូវវិនាសអន្តរាយទៅ ។ ចំពោះវាដែលបានស្វែងរកតែលួច សម្លាប់និងដើម្បីបំផ្លាញនោះ វាខ្លួនឯងនោះក៏ត្រូវវិនាសអន្តរាយទៅ ។

ព្រះយេស៊ូវទ្រង់បានធ្វើឱ្យពួកម្ចាស់នៃសេចក្ដីងងឹត និងពួកមានអំណាចនោះ ត្រូវបានបំផ្លាញទៅ ។

ព្រះគម្ពីរកូល៉ុស ២:១៥

ព្រះគម្ពីរនិក្ខមនំជំពូកទី១៥ ព្រះទ្រង់បានបើកសម្ដែងអង្គទ្រង់ដល់ពួកកូនចៅអ៊ីស្រាអែល ជាយេហូវ៉ារ៉ាហ្វា គឺជាអ្នកដែលប្រោសឱ្យជា ។ ពួកគេក៏បានលូតលាស់ឡើងដោយនូវចំណេះដឹងរបស់ពួកគេមកពីព្រះ ។ ឥឡូវនេះ ពួកគេស្គាល់ព្រះកាន់តែប្រសើរឡើង ។

### ខ. ជម្រើស

ព្រះគម្ពីរនិក្ខមនំ ១៥:២៦

ដូច្នេះ ព្រះទ្រង់សព្វព្រះហឫទ័យធ្វើការសម្រាប់ពួកកូនៗរបស់ឱ្យងទ្រង់ សូមឱ្យទូលបង្គំបានទទួលការបើកសម្ដែងពីដោយខ្លួនឯងចំពោះទ្រង់ផង ។ អញគឺជាយេហូវ៉ារ៉ាហ្វា ។ យេហូវ៉ា: គឺជាមួយព្រះអង្គដែលគង់នៅ គឺដែលបើកសម្ដែងដោយអង្គទ្រង់ផ្ទាល់ ។

ព្រះគម្ពីរទំនុកដំកើង ១០៥:៣៧

ប្រសិនបើព្រះទ្រង់មិនបានប្រោសឱ្យជា នៅថ្ងៃនេះទេ នោះយើងត្រូវតែផ្លាស់ប្រែដោយនូវព្រះនាមព្រះអង្គឡើង ។

វាមិនមែនជាការដែលអាចអនុវត្តបាន ដ៏យូរលង់នោះឡើយ ។

ព្រះគម្ពីរហេព្រើរ ១៣:៨

គ្រប់ការទាំងអស់នេះគឺជាលទ្ធភាព គឺដោយសារតែការយាងមកសុគតជំនួស នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទនោះឯង ។

## III. ការថ្លែងទំនាយរបស់ហោរាអេសាយ

### ក. ព្រះគម្ពីរអេសាយ ៥៣:១

"តើអ្នកណាដែលជឿលើការផ្សាយរបស់យើង?" ពេលដែលយើងសិក្សាពីការផ្សាយនេះ នោះយើងក៏មានការជ្រើសរើសដែរ ។ យើងអាចជឿនូវការផ្សាយនេះ និងទទួលកម្រៃដ៏ពេញលេញរបស់វា ឬក៏យើងអាចមានការសង្ស័យពីការផ្សាយនោះ ព្រមទាំងសុខចិត្តធ្វើការដោយគ្មានកម្រៃ ។

ព្រះគម្ពីរអេសាយ ៥៣:១ខ

អស់អ្នកដែលជឿនូវការផ្សាយនេះ នឹងបានត្រឡប់ទៅជាដៃរបស់ព្រះអម្ចាស់ ដូចជាគម្ពីរបានបើកសម្តែងរួចមកហើយ រីឯដៃរបស់ព្រះអម្ចាស់ នឹងបានចេញទៅដោយមានអំណាចចេស្តារបស់ផងព្រះអង្គ ។

ព្រះគម្ពីរអេសាយ ៥៣:៤-៥

ព្រះយេស៊ូវទ្រង់បានបង្គ្រប់ព្រះរាជកិច្ច របស់ព្រះអង្គរួចហើយ ។ ទ្រង់បានផ្ទុកអំពើបាបរបស់យើងដោយសារស្នាមជាំរបស់ផងព្រះអង្គ នោះយើងរាល់គ្នាបានជា ។ គ្រាន់តែជឿទៅលើការផ្សាយតែប៉ុណ្ណោះ ។ លោកអ្នកនឹងមិនត្រូវបង្កើតជម្ងឺរោគាតទៅទៀតឡើយ ។ ដោយសារស្នាមជាំរបស់ព្រះយេស៊ូវ នោះលោកអ្នកត្រូវបានប្រោសឱ្យជា ។

### ខ. តើព្រះនៃយើងទ្រង់មានពេញអំណាចចេស្តាយ៉ាងណាទៅ?

ព្រះគម្ពីរអេសាយ ៥៩:១

ហោរាអេសាយបានពណ៌នា ពីអំណាចចេស្តារបស់ព្រះសម្រាប់យើង ។

ព្រះគម្ពីរអេសាយ ៤៥:១២

ព្រះទ្រង់មានពេញគ្រប់ទាំងអំណាចព្រះចេស្តា! ដោយនូវព្រះពាហុទ្រង់ និងព្រះហស្តដែលទ្រង់បានលូកពីស្ថានសួគ៌មក ។ ព្រះយេស៊ូវដ៏ជាព្រះទ្រង់បានបើកសម្តែងមកក្នុងសាច់ឈាម ទ្រង់បានលូកព្រះហស្តរបស់របស់ទ្រង់ និងប្រោសអ្នកជម្ងឺឱ្យបានជា ។ ព្រះពាហុរបស់ទ្រង់គឺបានសម្តែងមកហើយ និងព្រះហស្តទ្រង់ក៏មិនរួញខ្លីដែលមិនអាចនឹងជួយសង្គ្រោះ និងប្រោសអ្នកឱ្យបានជានៅថ្ងៃនេះនោះដែរ ។

តើអ្នកណានឹងជឿបាន? គឺជាអស់អ្នកដែលបានទទួលនូវការបើកសម្តែងនោះឯង ។

### គ. ការឆ្លើយតប

គឺជាអស់អ្នកដែលជឿ នោះនឹងបានទទួលនូវការបើកសម្តែងដ៏ពេញលេញពីការផ្សាយនោះ ។ ពួកគេនឹងបញ្ជាក់ថាការប្រទានអំណាចរបស់ព្រះសម្រាប់ការប្រោសឱ្យជា គឺមានច្រើនផ្នែកណាស់ពីការងារប្រោសលោះ របស់ព្រះយេស៊ូវទៅលើផលប្រយោជន៍របស់ពួកគេនោះ គឺជាការប្រទានអំណាចសម្រាប់សេចក្តីសង្គ្រោះនោះឯង ។

ការយល់ដឹងផ្នែកខាងក្នុងនេះ គឺបានចូលមកដោយការបើកសម្តែងជាអធិធម្មជាតិ គឺជាភាពឆ្លើយមកពីសេចក្តីពិតរបស់ព្រះ ដោយនូវវិញ្ញាណរបស់យើង ក្នុងមួយរំពេចភ្លាម១ នោះទេ ។ ការបើកសម្តែង គឺមិនមែនមកតាមរយៈហេតុផល

អំណាចខាងឯបញ្ហារបស់យើងនោះទេ ។ ចូរចងចាំនូវពាក្យ "បើកសម្តែង" នេះ ។

ព្រះគម្ពីរអេសាយ ៥៣:៤

ពិតប្រាកដណាស់ ព្រះយេស៊ូវទ្រង់បានផ្ទុកនូវអំពើបាបរបស់យើង យើងមិនត្រូវផ្ទុកពួកវាតទៅទៀតទេ ។

ពិតប្រាកដផងដែរ ព្រះយេស៊ូវទ្រង់បានផ្ទុកនូវជម្ងឺ និងការឈឺចុកចាប់របស់លោកអ្នក ដូច្នេះ លោកអ្នកមិនត្រូវបានទទួលនាំយកពួកវានោះតទៅទៀតឡើយ ។

យើងបានទទួលនូវសេចក្តីពិតហើយថា "ទ្រង់បានរងរបួសសម្រាប់ការប្រព្រឹត្តរំលងរបស់យើង" ប៉ុន្តែ យើងរាល់គ្នាមិនបានអើពើដឹងពីសេចក្តីពិតនោះឡើយ អំពីព្រះបន្ទូលដែលថែងមកថា "ដោយសារស្នាមជាំរបស់ទ្រង់ នោះយើងរាល់គ្នាបានជា" សូម្បីតែតាមរយៈប្រយោគទាំងពីរនេះក៏ដោយក៏មានខគម្ពីរនិយាយដូចគ្នាដែរ ។

ព្រះគម្ពីរអេសាយ ៥៣:៥

វាគឺជាការងារដែលពេញលេញ ។ វាគឺត្រូវបានបញ្ចប់ហើយ ។ ប្រសិនបើការងាររបស់ទ្រង់ត្រូវបានពេញលេញហើយនោះ យើងក៏ត្រូវបានប្រោសឱ្យជាដែរ អញ្ចឹង យើងគឺត្រូវបានប្រោសឱ្យជាហើយ ។

## ឃ. គ្រាន់តែជឿនូវការផ្សាយនោះបានហើយ ។

"ជួនកាល ខ្ញុំមិនមានអារម្មណ៍ថាបានសង្គ្រោះទេ ប៉ុន្តែ ខ្ញុំដឹងថា ខ្ញុំបានសង្គ្រោះហើយ ពីព្រោះខ្ញុំបានជឿលើព្រះរាជសាររបស់ផងព្រះ" ។

ព្រះគម្ពីរ ១យ៉ូហាន ៥:១៣ក

ខ្ញុំត្រូវបានប្រោសឱ្យជាហើយ ពីព្រោះព្រះទ្រង់មានបន្ទូលយ៉ាងដូច្នោះ!

"ជួនកាល ខ្ញុំមិនមានអារម្មណ៍ថាបានប្រោសឱ្យជានោះទេ ប៉ុន្តែ ខ្ញុំដឹងថាខ្ញុំបានទទួលនូវការប្រោសឱ្យជាហើយ ពីព្រោះខ្ញុំជឿលើព្រះបន្ទូលរបស់ព្រះ" ។ ខ្ញុំមិនបានទៅដោយសារអារម្មណ៍របស់ខ្ញុំ ឬក៏ដោយសាររបាយការណ៍ពីគ្រូពេទ្យនោះទេ ។ សំណួរគឺ "តើលោកអ្នកជឿឬទេ?"

ព្រះគម្ពីរអេសាយ ៥៣:៥

យើងត្រូវតែទទួលនូវអ្វី ដែលត្រឹមត្រូវពេញលេញដែលជារបស់យើងនោះដោយសារសេចក្តីជំនឿ យ៉ាងហោចណាស់ក៏ពីអ្វីដែលយើងមានអារម្មណ៍ ឬក៏បានមើលឃើញ ។ យើងមិនត្រូវអនុញ្ញាតឱ្យការមិនជឿលើអ្នកដទៃទៀត ដែលមកលួចការប្រោសឱ្យជារបស់យើងនោះឡើយ ។

## ង. លោកម៉ាថាយបានជឿលើការផ្សាយនោះ

ព្រះគម្ពីរម៉ាថាយ ៨:១៦-១៧

## ច. លោកពេត្រុសបានជឿលើការផ្សាយនោះ

ព្រះគម្ពីរ ១ពេត្រុស ២:២៤

តើលោកអ្នកជឿឬទេ?

ព្រះគម្ពីរយ៉ាកុប ២:២៦

## ក្រុមពិភាក្សា

១. តើអ្វីទៅដែលពិតប្រាកដជាមានន័យថា "ចូរឈរឱ្យបានមាំមួន និងមើលឃើញសេចក្តីសង្គ្រោះរបស់ព្រះជាអម្ចាស់"?

២. តើយើងនឹងបានទៅជាមនុស្ស ដែលបើកឱ្យការមិនជឿលើអ្នកដទៃទៀត ដែលចូលមកលួចយកសេចក្តីសង្គ្រោះរបស់ពួកគេនោះ?

៣. ចូរចែកចាយនូវពាក្យរេម៉ាដើមទាំងពីរយ៉ាង ដែលមានការបើកសម្តែងក្រោយមកទៀត ចូលទៅក្នុងការធ្វើទីបន្ទាល់នោះ ។

## ការសិក្សាដោយខ្លួនឯង

១. តើលោកអ្នកបានទទួលនូវសេចក្តីពិត ដែលមានចែងមកថា "ទ្រង់បានរងរបួសសម្រាប់ការប្រព្រឹត្តរំលងរបស់អ្នក" ប៉ុន្តែ អ្នកបែរជាមិនអើពើដឹងពីសេចក្តីពិតនោះ ដែលចែងមកថា "ដោយសារស្នាមជាំរបស់ទ្រង់ នោះអ្នករាល់គ្នាបានជា" ហើយឬនៅ? ប្រសិនបើដូច្នោះមែន តើលោកអ្នកអាចបំផ្លាស់បំប្រែ នូវការដែលមិនរវល់នេះឬទេ?

២. នៅពេលដែលលោកអ្នក បានទទួលនូវព្រះលោហិតរបស់ព្រះយេស៊ូវ នោះលោកអ្នកក៏ត្រូវបានដោះឱ្យរួចផងដែរ ។ វាគឺជាពេលវេលាសម្រាប់លោកអ្នក ឱ្យបានដោះនូវចំណងពីស្រុកអេស៊ីព្ទនោះចេញហើយ ។

ក. តើលោកអ្នកនឹងប្រឹក្សាពីចំណងស្រុកអេស៊ីព្ទនោះឬ?

ខ. ចូរចាប់ផ្តើមប្រកាសពីការបង់ថ្លៃរបស់ព្រះគ្រីស្ទ ឱ្យយើងបានរួចពីស្ថានការណ៍នោះ និងបានមើលឃើញថា តើនឹងមានការផ្លាស់ប្រែយ៉ាងណានោះ ។

៣. តើការពិសោធន៍អ្វីខ្លះដែលលោកអ្នកមាន ជាមួយនឹងពាក្យ "យេហូវ៉ារ៉ាហ្វា" នោះ? ចូរសរសេរចុះនូវ ពាក្យពីរបីម៉ាត់ ដើម្បីឱ្យពាក្យទាំងនោះបានលើកទឹកចិត្តលោកអ្នក ក្នុងពេលក្រោយៗមកទៀត ។

# ការប្រទានអំណាចរបស់ព្រះ សម្រាប់ការប្រោសឱ្យជា

## *មេរៀនទី ៣: ព្រះយេស៊ូវ ទ្រង់គឺជាគំរូរបស់យើង*

នៅគ្រានអតីតកាល ពួកបណ្ឌិតជនបានប្រាប់ខ្ញុំថា ព្រះយេស៊ូវទ្រង់គឺជាគំរូរបស់យើង ។ ខ្ញុំមិនអាចនិយាយរៀបរាប់ពីរឿងនោះបានទេ ។ ខ្ញុំបានគិតថា "ព្រះយេស៊ូវទ្រង់គឺជាព្រះរាជបុត្រានៃព្រះ ហើយខ្ញុំទើបនឹងបានជាកូនមនុស្ស" ។ ព្រះយេស៊ូវទ្រង់បានសម្តែងពីគ្រប់គ្នាទាំងអស់ ដែលមានការស្រមើស្រមៃនូវការធ្វើការអស្ចារ្យនៅលើផែនដី ។ ប្រសិនបើខ្ញុំអាចមើលឃើញការទាំងនោះដែរទៅហ្ន៎! តើទ្រង់អាចបានទៅជាគំរូរបស់ខ្ញុំច្រើនប៉ុណ្ណាទៅ? តើការធ្វើការអស្ចារ្យបានទាក់ទងនឹងខ្ញុំដែរឬទេនៅថ្ងៃនេះ?

## I. ព្រះយេស៊ូវគឺជាមនុស្ស

ព្រះយេស៊ូវទ្រង់គឺជា និងតែងតែជាព្រះរាជបុត្រានៃព្រះដ៏អស់កល្បជានិច្ច ។ វាគឺជាការសំខាន់ដើម្បីឱ្យយល់ថា ព្រះយេស៊ូវទ្រង់គឺបានគង់នៅខាងស្តាំរបស់ព្រះ គឺត្រឹមតែបណ្តោះអាសន្ននៅក្នុងបែលដែលទ្រង់យាងមកផែនដីនោះទេ ។ គឺទ្រង់បានយាងមកឱ្យមានភាពដូចមនុស្សសុទ្ធសាធ គឺជាលោកអ័ដាមចុងក្រោយ ដែលជាកូនមនុស្ស ។ ទ្រង់គឺនៅតែជាព្រះរាជបុត្រានៃព្រះដដែលទេ ប៉ុន្តែ ដែលទ្រង់បានដើរនៅលើផែនដីនេះ គឺជាមនុស្សៈ ព្រះយេស៊ូវ ។ ទ្រង់គឺជាព្រះ ទ្រង់បានជ្រាបពីគ្រប់យ៉ាង ទ្រង់មានព្រះវត្តមានគ្រប់ទីកន្លែង ។ ទោះជាយ៉ាងណាក៏ដោយ គ្រប់យ៉ាងដែលទ្រង់បានធ្វើនៅផែនដី គឺទ្រង់បានអនុវត្តជាលោកអ័ដាមទីមួយ ដែលត្រូវបានបង្កើតមកឱ្យអនុវត្តការងារនោះ ។ ព្រះយេស៊ូវទ្រង់បានអនុវត្តការងារជាមនុស្ស គឺដែលបង្ហូរមកដោយនូវព្រះវិញ្ញាណបរិសុទ្ធ គឺដូចជាពួកអ្នកជឿ ដែលត្រូវតែអនុវត្តការងារនៅសម័យសព្វថ្ងៃនេះដែរ ។

លោកសាវ័កប៉ុលបានសរសេរ អំពីការយាងមកជាមនុស្សរបស់ព្រះយេស៊ូវ ។

ព្រះគម្ពីរភីលីព ២:៧

ទ្រង់គឺជាព្រះមួយរយភាគរយ គឺគ្មានផ្លូវប្រឌិតឯណាទៀតទេ គឺទ្រង់បានមកជាទទេដោយអង្គទ្រង់ពីសិទ្ធិដើមរបស់ផងទ្រង់ដ៏ជាព្រះ គឺគ្រាន់តែជាបណ្តោះអាសន្នប៉ុណ្ណោះ ព្រមទាំងបានដើរលើផែនដីនេះជាមនុស្សសុទ្ធសាធនោះឯង ។ ព្រះទ្រង់បានប្រទានដល់មនុស្សនូវអំណាចគ្រប់គ្រងលើផែនដី និងគ្រប់របស់ទាំងអស់ដែលនៅលើផែនដីនោះឯង ។ គឺជាការមានបញ្ហា ដែលជាលទ្ធផលនៃអំពើបាបនៅលើផែនដីនេះតែប៉ុណ្ណោះ ។ មានតែផ្លូវមួយទេដែលព្រះទ្រង់អាចនឹងជួសជុលនូវអំពើបាបគឺជាបញ្ហានេះបាន គឺទ្រង់ត្រូវតែយាងមកផែនដីនេះកើតជាមនុស្ស ។ ព្រះយេស៊ូវទ្រង់គឺជាព្រះដែលមាន "សព្វវត្តមាន" (ទ្រង់មានព្រះវត្តមានគ្រប់ទីកន្លែង) ។ ប៉ុន្តែ នៅពេលដែលទ្រង់បានយាងមកផែនដីនេះ គឺទ្រង់អាចបានត្រឹមតែចាប់យកនៅពេលវេលាមួយនេះឯង ។ ភាពជាព្រះរបស់ទ្រង់គឺទ្រង់បាន "ជ្រាបពីគ្រប់ការទាំងអស់" គឺ (ទ្រង់បានជ្រាបពីគ្រប់ការទាំងអស់) ។ ទ្រង់គឺជាមនុស្ស គឺទ្រង់មានចំណេះដឹងជាកំណត់ក្នុងភាពជាមនុស្សនោះ ។ យើងមើលឃើញគំរូពីការទាំងនេះ គឺនៅពេលដែលមនុស្សស្រីម្នាក់

ដែលបានធ្លាក់ឈាមអស់រយៈកាល១២ឆ្នាំមកហើយ បានមកប៉ះពាល់ព្រះអង្គ គឺនាងបានប៉ះពាល់ទ្រង់ដោយសេចក្តីជំនឿ ។

### ក. តើអ្នកណាបានពាល់ខ្ញុំ?

ព្រះគម្ពីរម៉ាកុស ៥:២៥-៣៤

អំណាចចេស្តាដែលបានបង្ហូរចេញពីព្រះយេស៊ូវ គឺជាពិតប្រាកដណាស់ និងជាការជាក់ស្តែង ដែលវាជាការបណ្តាលឱ្យទ្រង់បានឈប់ទ្រឹង ហើយក៏សួរថា "តើអ្នកណាបានពាល់សម្លៀកបំពាក់ខ្ញុំ?" ហេតុអ្វីបានជាព្រះយេស៊ូវទ្រង់ត្រូវតែសួរ? តើទ្រង់មិនជ្រាបពីអ្វីទាំងអស់ឬ? ទេ គឺកំឡុងពេលដែលទ្រង់បានគង់នៅលើផែនដីនេះតែប៉ុណ្ណោះ គឺទ្រង់បានអនុវត្ត ដូចជាលោកអ្នក និងខ្ញុំដែរ ។

### ខ. ស្រីសាសន៍សាម៉ារីនៅឯមាត់អណ្តូង

ព្រះគម្ពីរយ៉ូហាន ៤:១៧-១៨

តើព្រះយេស៊ូវទ្រង់ជ្រាបពីការនេះ ដោយរបៀបណា? ទ្រង់គឺជាមនុស្ស ទ្រង់បានអនុវត្តតាមអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ គឺទ្រង់បានទទួលនូវពាក្យសម្តីនៃចំណេះចេះស្ទាត់ ។

ព្រះយេស៊ូវ ទ្រង់គឺជាព្រះដែលមានគ្រប់ទាំងអំណាចព្រះចេស្តា (ទ្រង់មានគ្រប់ទាំងអំណាចព្រះចេស្តា) ។ ទ្រង់មានព្រះបន្ទូល ហើយលោកិយទាំងមូលគឺត្រូវតែក្រាបចុះ ។ ទោះជាយ៉ាងណាក៏ដោយពេលដែលព្រះយេស៊ូវទ្រង់បានទទួលពិធីជ្រមុជទឹកនៅក្នុងទន្លេយ័រដាន ក្រោយពេលដែលទ្រង់បានយាងឡើងចេញពីទឹកមក នោះព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើទ្រង់ ។ ចាប់តាំងពីថ្ងៃនោះមកក៏មានការធ្វើការអស្ចារ្យកាន់តែកើនឡើងៗ គឺមិនមែនដោយនូវអំណាចរបស់ទ្រង់ផ្ទាល់ដែលជាព្រះនោះទេ គឺជាមនុស្សដែលបានពេញដោយអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធវិញ ។ ឥឡូវនេះខ្ញុំបានអានដំណឹងល្អ ហើយក៏បានស្រមើស្រមៃដោយខ្លួនឯងពីអ្វីដែលព្រះយេស៊ូវទ្រង់បានធ្វើ គឺសារតែព្រះវិញ្ញាណបរិសុទ្ធដដែល ដែលទ្រង់បានយាងមកសណ្ឋិតលើខ្ញុំដែលបាននៅក្នុងព្រះយេស៊ូវនោះ ។ ខ្ញុំជាអ្នកជឿដែលមានពេញដោយព្រះវិញ្ញាណបរិសុទ្ធ គឺខ្ញុំបានមានព្រះវិញ្ញាណបរិសុទ្ធដដែលដែលគង់នៅក្នុងខ្ញុំ ។ សេចក្តីពិតនោះគឺបានបំផ្លាស់បំប្រែនូវផ្លូវដែលខ្ញុំបានអានព្រះគម្ពីរម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន ។ ឥឡូវនេះ ខ្ញុំអាចរៀបរាប់ទូលថ្វាយព្រះយេស៊ូវដ៏ជាគំរូរបស់ខ្ញុំ ។ ឥឡូវនេះ ខ្ញុំអាចមើលឃើញដោយខ្លួនឯងនូវទង្វើនៃការងារ ដូចគ្នាដែលព្រះយេស៊ូវទ្រង់បានធ្វើដែរ ។ ប្រសិនបើព្រះយេស៊ូវទ្រង់អាចធ្វើការអស្ចារ្យទាំងនោះបាន ក្នុងភាពជាមនុស្សដែលបានពេញដោយនូវអំណាចចេស្តា នៃព្រះវិញ្ញាណបរិសុទ្ធ នោះលោកអ្នកនិងខ្ញុំដែលជាមនុស្សប្រុសស្រី ដែលបានពេញដោយនូវអំណាចចេស្តា នៃព្រះវិញ្ញាណបរិសុទ្ធដែរនោះ ក៏អាចធ្វើការអស្ចារ្យនោះបានដែរ ។

ព្រះគម្ពីរយ៉ូហាន ១៤:១២

## II. ការអស្ចារ្យទាំងពីរជាដំបូងរបស់ព្រះយេស៊ូវ

### ក.ការធ្វើទឹកឱ្យទៅជាស្រាទំពាំងបាយជូរ

ការអស្ចារ្យលើកទីមួយ ដែលបានបញ្ជាក់ដោយនូវព្រះយេស៊ូវ នោះគឺជាការធ្វើទឹកឱ្យទៅជាស្រាទំពាំងបាយជូរ គឺជាការអស្ចារ្យនៅក្នុងពិធីបុណ្យ ។ បន្ទាប់ពីនាងម៉ារាដែលជាមាតារបស់ព្រះយេស៊ូវ បានទូលប្រាប់ដល់ទ្រង់ថា ពួកគេអស់

ស្រាទំពាំងបាយជូរហើយ គឺនាងបាននិយាយពាក្យដ៏សំខាន់ ខ្លះៗ ប្រាប់ដល់ពួកអ្នកបម្រើ ។ ស្រាទំពាំងបាយជូរ គឺជាតំណាងឱ្យព្រះវិញ្ញាណបរិសុទ្ធ ។ មានគ្រឹស្ទានជាច្រើនបានអស់ស្រាទំពាំងជូរ ។

ព្រះគម្ពីរយ៉ូហាន ២:១-៥

ដើម្បីឱ្យបានទទួលនូវការពិសោធន៍ នូវការធ្វើការអស្ចារ្យរបស់ព្រះយេស៊ូវនៅក្នុងជីវិតរបស់យើង នោះយើងត្រូវតែស្តាប់សម្លេងរបស់ព្រះ ហើយប្រញាប់ប្រញាល់ស្តាប់បង្គាប់យ៉ាងហោចណាស់ក៏ជារបៀប ដែលនាំឱ្យមានសេចក្តីចំកួតដែលអាចនឹងកើតមានឡើងបាន ។ "អ្វីក៏ដោយដែលទ្រង់បានប្រាប់ឱ្យធ្វើ នោះចូរធ្វើចុះ!" យើងគឺជាអ្នកស្តាប់បង្គប់ព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធ នោះនឹងធ្វើការតាមរយៈយើងរាល់គ្នា ។

ពួកអ្នកបម្រើបានស្តាប់បង្គាប់ព្រះយេស៊ូវ ពួកគេបានចាក់បំពេញទឹកទៅក្នុងពាង ។ ពួកគេនៅតែស្តាប់បង្គាប់ដល់ព្រះអង្គ ដោយបានចាក់ទឹក និងដងទឹកយកទៅជូនម្ចាស់មង្គលការ ។ ពេលដែលម្ចាស់បានភ្លក់ហើយ គាត់ក៏បាននិយាយថា "អ្នកបានទុកស្រាល្អនេះរហូតមកដល់ពេលនេះ" ។

តើវាជាការងាយស្រួលដោយរបៀបណាទៅ ដែលបានធ្វើការនោះដោយមានការសង្ស័យ គឺនៅពេលដែលព្រះយេស៊ូវទ្រង់មានបន្ទូលប្រាប់ពួកគេឱ្យចាក់ទឹក និងដងយកទៅជូនដល់ម្ចាស់មង្គលការនោះ ។ ពួកអ្នកបម្រើមិនត្រឹមតែបានចាប់ផ្តើមស្តាប់បង្គាប់ដល់ទ្រង់ប៉ុណ្ណោះទេ គឺពួកគេបានទាំងធ្វើបន្តទាំងពេលដែលពួកគេមិនបានយល់នោះទៀតផង!

ដើម្បីឱ្យមានការពិសោធន៍នូវការធ្វើការអស្ចារ្យ នៅក្នុងជីវិតរបស់យើង នោះយើងត្រូវតែនិយាយផងដែរថា "អ្វីដែលទ្រង់បានប្រាប់ដល់ខ្ញុំ នោះខ្ញុំនឹងត្រូវតែធ្វើ!"

**ខ. ការប្រោសឱ្យជាដល់កូនប្រុសរបស់អភិជនម្នាក់**

ការប្រោសឱ្យជា គឺជាការអស្ចារ្យលើកទីពីររបស់ព្រះយេស៊ូវ!

អភិជនម្នាក់នេះក៏បានស្តាប់ឮអំពីការអស្ចារ្យ ដែលព្រះយេស៊ូវទ្រង់បានធ្វើនៅក្នុងពិធីមង្គលការ ហើយការឮនោះក៏បាននាំមកនូវសេចក្តីជំនឿដែរ ។ ជាលទ្ធផលនៃសេចក្តីជំនឿនោះ គឺជាការស្លាប់នៃកូនរបស់គាត់ ត្រូវបានរស់នៅវិញ។

ព្រះគម្ពីរយ៉ូហាន ៤:៤៦-៥១

មនុស្សដែលមិនបានទទួលជោគជ័យ នៅក្នុងការបញ្ចុះបញ្ចូលដល់ព្រះយេស៊ូវ ឱ្យទ្រង់បានប្រោសកូនប្រុសរបស់គាត់បានជាតាមមធ្យោបាយរបស់គាត់នោះទេ ។ គាត់បានទូលសុំឱ្យទ្រង់បានយាងមកប្រោសកូនប្រុសរបស់គាត់ឱ្យជា ។ ជំនួសឱ្យនូវការនេះ បុរសនោះក៏បានទទួលនូវការអស្ចារ្យនៃការប្រោសឱ្យជា គឺនៅពេលដែលគាត់បានជឿនូវពាក្យ ដែលព្រះយេស៊ូវទ្រង់មានបន្ទូលនោះឯង!

មានមនុស្សជាច្រើនបានធ្លាក់ចុះ នូវការពិសោធន៍នៃការធ្វើការអស្ចារ្យនេះ ពីព្រោះពួកគេបានព្យាយាមបញ្ចុះបញ្ចូលព្រះយេស៊ូវឱ្យទ្រង់បានធ្វើការតាមមធ្យោបាយរបស់ពួកគេ ។ ពួកគេជឿថា ពួកគេនឹងទទួលបាននូវការប្រោសឱ្យជា ប្រសិនបើមនុស្សបានអធិស្ឋានឱ្យបានពិតប្រាកដ សម្រាប់ពួកគេតាមមធ្យោបាយដ៏ពិតប្រាកដ ជំនួសសេចក្តីជំនឿដ៏ពិត លើព្រះនិងលើបន្ទូលរបស់ទ្រង់នោះ ។

ដូចជាពួកអ្នកបម្រើនិងអភិជនម្នាក់នោះ និងយើងផងដែរ គឺអាចមានបទពិសោធន៍មួបការអស្ចារ្យ ប្រសិនបើយើងបានស្តាប់សម្លេងរបស់ព្រះយេស៊ូវ ហើយជឿលើព្រះបន្ទូលដែល

ទ្រង់បាននិយាយ ព្រមទាំងស្តាប់បង្គាប់នូវអ្វីដែលទ្រង់មានបន្ទូលប្រាប់ឱ្យយើងធ្វើនោះ ។

## III. ព្រះយេស៊ូវទ្រង់បានយាងមក

### ក. ការដោះឱ្យមានសេរីភាព!

ព្រះយេស៊ូវទ្រង់បានទទួលការចាក់ប្រេងតាំង ដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីផ្សាយដំណឹងល្អ រំដោះដល់អ្នកជាប់ទោសឱ្យបានរួចខ្លួន និងដោះដល់អ្នកត្រូវសង្កត់សង្កិនឱ្យមានសេរីភាព ។ គ្រប់ទាំងចំណងគឺរួមបញ្ចូលទាំងចំណងនៃជម្ងឺ និងចំណងនៃពិការភាព ដែលនាំឱ្យគេមិនដែលបានធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះនោះឯង គឺចាប់តាំងពីបានទទួលនូវការចាក់ប្រេងតាំងដោយព្រះវិញ្ញាណបរិសុទ្ធ គឺត្រូវតែបានទទួលនូវការប្រោសឱ្យជា និងត្រូវបានដោះឱ្យមានសេរីភាព ។

ព្រះគម្ពីរលូកា ៤:១៤

ព្រះយេស៊ូវទ្រង់បានយាងចូលទៅក្នុងព្រះវិហារ របស់ពួកសាសន៍យូដា ព្រមទាំងបានអានគម្ពីរពួកហោរាអំពីរឿងព្រះអង្គទ្រង់ផ្ទាល់ពីហោរាអេសាយ ។ ព្រះគម្ពីរលូកា ៤:១៨ ។

### ខ. ការបំបាក់បំបែកនឹម

ហោរាអេសាយបានថ្លែងទំនាយពីព្រះរាជកិច្ចព្រះយេស៊ូវដែលទ្រង់នឹងបានដោះនូវការក្បៀបសង្កត់ ឱ្យមានសេរីភាពឡើងវិញ ។ ព្រះគម្ពីរអេសាយ ៥៨:៦ ។

### គ. ការបំផ្លាញការងាររបស់សាតាំង

តាមព្រះគម្ពីរយ៉ូហាន គឺនិយាយពីមូលហេតុដែលព្រះយេស៊ូវទ្រង់បានយាងមក ។

ព្រះគម្ពីរ ១យ៉ូហាន ៣:៨ខ

គ្រប់ទីកន្លែងដែលព្រះយេស៊ូវទ្រង់បានយាងទៅដល់ គឺទ្រង់បានបំផ្លាញការងាររបស់អារក្ស ដែលវាមកប្រយោជន៍តែនឹងសម្លាប់ និងដើម្បីលួច ដោយការបំផ្លាញជម្ងឺ និងជម្ងឺរោគានោះឯង ។

### ឃ. ការប្រទានជីវិតអស់កល្បជានិច្ច

ដោយការបំផ្លាញការងាររបស់អារក្ស នោះព្រះយេស៊ូវទ្រង់បានប្រទាននូវជីវិតអស់កល្បជានិច្ច សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលថា

ព្រះគម្ពីរយ៉ូហាន ១០:១០ខ

### ង. ការប្រោសពួកគេទាំងអស់គ្នាឱ្យបានជា

ការបើកសម្តែងពីព្រះគម្ពីរទៅលើការប្រោសឱ្យជា នោះគឺជាព្រះរាជកិច្ចរបស់ព្រះយេស៊ូវ គឺដែលទ្រង់បានប្រោសអស់អ្នកទាំងអស់ដែលមកឯទ្រង់នោះ ឱ្យបានជា ។

នៅក្នុងព្រះគម្ពីរ គឺមានគោលរឿងសំខាន់ៗ ដែលបានពណ៌នាពីសេចក្តីសង្គ្រោះ និងការប្រោសឱ្យជា ។ គោលរឿងនោះគឺបានពណ៌នាពីអ្នកដែលត្រូវបានប្រោសឱ្យជា គឺស្រដៀងទៅនឹងគោលរឿងដែលពណ៌នាពីអស់អ្នក ដែលត្រូវបានកើតជាថ្មីនោះឯង ។

***ចំពោះសេចក្តីសង្គ្រោះ: គឺដល់គ្រប់គ្នាទាំងអស់***

***ចំពោះការប្រោសឱ្យជា: គឺដល់គ្រប់គ្នាទាំងអស់***

មានព្រះគម្ពីរដែលបានបង្ហាញថា ការប្រោសឱ្យជា គឺសម្រាប់គ្រប់គ្នាទាំងអស់ ។ ពេលដែលលោកអ្នកបានអាននូវខទាំងនេះ ហើយរុករកឱ្យឃើញ នូវការបើកសម្តែងទៅលើគោលរឿងទាំងនោះ "គ្រប់គ្នា" "ទាំងអស់គ្នា" ។

**១. គ្រប់គ្នា**

ព្រះគម្ពីរម៉ាថាយ ៩:៣៥

**២. ជាច្រើន**

ព្រះគម្ពីរម៉ាថាយ ១៤:៣៦

**៣. ទាំងអស់គ្នា**

ព្រះគម្ពីរម៉ាថាយ ១២:១៥

ព្រះគម្ពីរម៉ាថាយ ៨:១៦

ព្រះគម្ពីរលូកា៦:១៩

ព្រះគម្ពីរកិច្ចការ១០:១៩

**៤. ទ្រង់មិនដែលប្រែប្រួលឡើយ!**

អ្នកនិពន្ធព្រះគម្ពីរហេព្រើរ បានសរសេរចែងទុកមកថា ព្រះយេស៊ូវទ្រង់មិនដែលប្រែប្រួលឡើយ ទ្រង់គឺនៅតែដដែល គឺចាប់ពីថ្ងៃនេះ ។

ព្រះគម្ពីរហេព្រើរ ១៣:៨

ប្រសិនបើទ្រង់បានប្រោសឱ្យជា គឺនៅពេលដែលទ្រង់គង់នៅលើផែនដីនេះ នោះទ្រង់នឹងប្រោសឱ្យជានៅថ្ងៃនេះ! គ្រប់គ្នាដែលចូលមកឯទ្រង់ដោយសេចក្តីជំនឿ នោះគឺអាចទទួលនូវការប្រោសឱ្យជា ។

## IV. ព្រះយេស៊ូវទ្រង់បានប្រទាននូវមហាព្រះរាជបញ្ជា

### ក. ឥឡូវនេះខ្ញុំនឹងទៅឯព្រះវរបិតាខ្ញុំ

ព្រះគម្ពីរយ៉ូហាន ១៦:៧

ព្រះគម្ពីរយ៉ូហាន ១៤:១២

### ខ. សេចក្តីបង្រៀនចុងក្រោយ

នៅលើភ្នំដើមអូលីវ គឺមុនពេលដែលព្រះយេស៊ូវទ្រង់បានត្រូវលើកឡើងទៅឯស្ថានសួគ៌ ។ ទ្រង់បានប្រទានឱ្យយើងនូវសេចក្តីបង្រៀនចុងក្រោយរបស់ព្រះអង្គ ។ គឺយើងត្រូវបានត្រាស់ហៅមកឱ្យបំពេញ នូវមហាព្រះរាជបញ្ជានេះ ។

លោកម៉ាកុសបានកត់ត្រាសេចក្តីសំខាន់ទាំងនេះ គឺជាពាក្យចុងក្រោយរបស់ព្រះយេស៊ូវ ទៅដល់ពួកអ្នកជឿរបស់ផងព្រះអង្គ ។

ព្រះគម្ពីរម៉ាកុស ១៦:១៥-២០

ការនេះគឺមិនមែនគ្រាន់តែជាសំណូមពរនោះទេ គឺជាព្រះរាជបញ្ជាវិញ! គឺនៅថ្ងៃទី៥០ បន្ទាប់ការទទួលនូវអំណាចព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ គឺពួកគេបានចាប់ផ្តើមយល់ដឹងពីអ្វីដែលព្រះយេស៊ូវទ្រង់បានប្រាប់ដល់ពួកគេ ។

### គ. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវគឺរួមបញ្ចូលទាំង:

**១. ការបង្រៀន**

**២. ការផ្សាយដំណឹងល្អ**

**៣. ការប្រោសឱ្យជា និងការរំដោះ ។**

ព្រះគម្ពីរម៉ាថាយ ៩:៣៥-៣៨

ពួកគេបានឃ្លាំមើលព្រះយេស៊ូវទ្រង់បានផ្សាដំណឹងល្អ និងបានប្រោសឱ្យជាអស់រយៈពេលបីឆ្នាំ ។ ឥឡូវនេះ ព្រះរាជកិច្ចរបស់ព្រះអង្គបានពេញគ្រប់គ្រាន់ហើយ ។

## V. ព្រះយេស៊ូវទ្រង់បានបញ្ជាពួកសិស្សឱ្យចេញបេសកកម្ម

ព្រះរាជកិច្ចរបស់ព្រះយេស៊ូវ គឺត្រូវបានកំណត់ពីភូមិមួយទៅភូមិមួយ ពីទីក្រុងមួយទៅទីក្រុងមួយនៅក្នុងពេលរបស់ទ្រង់ ។ វាគឺមិនមែនជាការដែលគ្មានលទ្ធភាពសម្រាប់ទ្រង់

នោះឡើយ ក្នុងការឈោងចាប់ឱ្យបានជាពហុគុណគ្រប់ទីក្រុងទាំងអស់ ។ ទ្រង់បានបង្រៀនពួកសិស្សឱ្យចេះអធិស្ឋានសម្រាប់អ្នកដទៃ ក្នុងការបញ្ជូនអ្នកធ្វើការប្រមូលផល ។

## ក. ពួកសិស្ស

ព្រះរាជកិច្ចជាអធិធម្មជាតិរបស់ព្រះយេស៊ូវ គឺត្រូវបានជាពហុគុណ ដូចជាទ្រង់បានព្រះរាជបញ្ជាដល់ពួកសិស្សទាំង១២នាក់ ។ ពួកគេក៏បានចេញបំពេញការងារតាមព្រះរាជបញ្ជាដែលទ្រង់បានបង្គាប់ទុកមកនោះ ។

ព្រះគម្ពីរម៉ាថាយ ១០:១,៧-៨

ក៏មានព្រះរាជបញ្ជាថ្មីៗទៀតដល់ពួកសិស្សដែលត្រូវធ្វើ:

**១. ផ្សាយដំណឹងល្អ**

**២. ប្រោសអ្នកជម្ងឺឱ្យជា**

**៣. សម្អាតពួកអ្នកមានជម្ងឺឃ្លង់ឱ្យបានជាស្អាត**

**៤. ប្រោសអ្នកស្លាប់ឱ្យរស់ឡើងវិញ ។**

**៥. បណ្តេញពពួកវិញ្ញាណអាក្រក់ ។**

ពួកគេត្រូវតែធ្វើការនេះដោយសេរី ព្រមទាំងមានសេចក្តីស្រឡាញ់ដូចៗគ្នា និងសេចក្តីមេត្តាករុណាដែលព្រះយេស៊ូវទ្រង់បានធ្វើ ។ ការបំពេញការងាររបស់ពួកគេ គឺត្រូវតែដូចគ្នានឹងព្រះរាជកិច្ចរបស់ព្រះយេស៊ូវទ្រង់បានធ្វើដែរ ។

## ខ. ពួក៧០នាក់

បន្ទាប់ពីពួកសិស្សទាំង១២នាក់ បានទទួលព្រះរាជបញ្ជាហើយ ព្រមទាំងមានការលូតលាស់ក្នុងការពិសោធន៍ហើយ ព្រះយេស៊ូវទ្រង់ក៏បានបញ្ជូនពួក៧០នាក់ ឱ្យដើទៅទៀត ។

ព្រះគម្ពីរលូកា ១០:១,៩

ហើយប្រោសអ្នកជម្ងឺដែលនៅទីនោះឱ្យបានជា ព្រមទាំងមានបន្ទូលទៅពួកគេថា "នគរព្រះជិតមកដល់អ្នករាល់គ្នាហើយ" ។

ព្រះរាជបញ្ជានេះគឺមិនដែលផ្លាស់ប្តូរឡើយ ។ អ្នកទាំង៧០នាក់នោះគឺត្រូវតែ:

**១. ប្រោសអ្នកជម្ងឺឱ្យជា**

**២. ផ្សាយដំណឹងល្អពីនគរព្រះ ។**

ការបំពេញការងារគឺត្រូវតែបានចំណាយពេលវេលា ។ ព្រះយេស៊ូវទ្រង់បានបម្លងពីទីមួយដោយព្រះអង្គទ្រង់ ឱ្យចូលទៅក្នុងជីវិតរបស់ពួកសិស្សទាំង១២នាក់ បន្ទាប់មក ទ្រង់បានបញ្ចូលទៅក្នុងជីវិតអ្នកទាំង៧០នាក់ទៀត ។ ពិតប្រាកដណាស់ ពួកគេបាននៅតែសិក្សារៀនសូត្រឱ្យបានរីកលូតលាស់ថែមទៀត ។ ជាការសំខាន់បំផុតនោះ ពួកគេត្រូវតែមានការស្តាប់បង្គាប់ដល់ព្រះយេស៊ូវ ។ ជាលទ្ធផលគឺពួកគេបានទទួលនូវការពិសោធន៍ពីការអស្ចារ្យដ៏ធំបំផុត គេមានសេចក្តីអំណរនិងមានជ័យជម្នះ ។

ព្រះគម្ពីរលូកា ១០:១៧ក

គ្មានសេចក្តីអំណរណា ឱ្យដូចជាសេចក្តីអំណរដែលបានធ្វើការអធិស្ឋានដាក់លើអ្នកជម្ងឺ ហើយមើលឃើញពួកគេបានទទួលនូវការប្រោសឱ្យជា ព្រមទាំងបានផ្សាយដំណឹងល្អផងដែរ ។ ឥឡូវនេះ ព្រះរាជបញ្ជានេះ គឺបានត្រូវប្រទានឱ្យមកអ្នកជឿគ្រប់ៗរូប ។

ព្រះគម្ពីរម៉ាថាយ ២៨:១៤

ការងាររបស់ព្រះយេស៊ូវដែលនៅលើផែនដីនេះ គឺពេញលេញហើយ ។ ឥឡូវនេះ ព្រះយេស៊ូវទ្រង់បានរង់ចាំយើងឱ្យយើងបានទទួលនូវការងាររបស់យើង ដែលបានធ្វើ

សម្រេច ។ អ្នកជឿគ្រប់រូបគឺត្រូវតែ "ផ្សាយដំណឹងល្អ" ឬចែកចាយនូវដំណឹងល្អ ។ ក៏ដូចគ្នាដែរ ទីសម្គាល់ដែលជាប់តាមព្រះយេស៊ូវ គឺដែលទ្រង់បានផ្សាយដំណឹងល្អ នោះត្រូវតែជាប់តាមយើង ដែលជាពួកអ្នកជឿនៅសម័យសព្វថ្ងៃនេះ ។

## VI. អ្នកដឹកនាំពួកជំនុំដើមគឺនៅតែបន្តការប្រោសឱ្យជា

បន្ទាប់ពីព្រះយេស៊ូវទ្រង់បានត្រូវលើកឡើង ទៅឯស្ថានសួគ៌ តើការប្រោសឱ្យជាត្រូវបានបញ្ឈប់ឬ? ទេមិនមែនឡើយ គឺពួកសិស្សនៅតែបានបន្តការផ្សាយដំណឹងល្អ និងប្រោសអ្នកជម្ងឺឱ្យជា ។ ទីនេះគឺយើងមានការប្រឹក្សាពីគំរូរបស់លោកពេត្រុសភីលីព និងលោកប៉ុល ។

### ក. លោកសាវ័កពេត្រុស

លោកសាវ័កពេត្រុសបាននិយាយ ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ទៅដល់មនុស្សដែលមានចិត្តរឹង ឱ្យគេបានទទួលនូវការប្រោសឱ្យជា ។

ព្រះគម្ពីរកិច្ចការ ៣:១-៨

ការធ្វើការអស្ចារ្យក៏បានចាប់ផ្ដើមចេញ ទៅតាមផ្លូវថ្នល់ ។ ហើយការអស្ចារ្យនោះ ក៏នៅតែបានបន្ត ។

### ខ. លោកភីលីព

លោកភីលីពគឺជាអ្នកជំនួយ ដែលក្រោយមកគាត់បានត្រឡប់ទៅជាអ្នកផ្សាដំណឹងល្អ ដែលបានស្ដាប់បង្គាប់ដល់ព្រះយេស៊ូវ ព្រមទាំងបានផ្សាយដំណឹងល្អពីព្រះយេស៊ូវគ្រីស្ទ ទៅដល់អស់អ្នកនៅក្រុងសាម៉ារី និងបានធ្វើការអស្ចារ្យក្នុងការប្រោសឱ្យជាបាន ។ ព្រះគម្ពីរកិច្ចការ ៨:៥-៨ ។

ហេតុអ្វីបានជាពួកគេចំណាយពេលវេលាប្រុងប្រយ័ត្ន ទៅនឹងលោកភីលីពវិញ? គឺដោយព្រោះតែពួកគេបានឃើញ នូវការអស្ចារ្យ ហើយនៅទីនោះក៏សេចក្ដីដ៏លើសលុបផងដែរ ។

### គ. លោកសាវ័កប៉ុល

លោកសាវ័កប៉ុលបានផ្សាយដំណឹងល្អ ពីព្រះយេស៊ូវគ្រីស្ទទៅដល់មនុស្សពិការ ហើយមនុស្សនោះក៏ត្រូវបានទទួលនូវការប្រោសឱ្យជា ។

ព្រះគម្ពីរកិច្ចការ ១៤:៨-១០

គាត់បានប្រោសដល់មនុស្សមានជម្ងឺគ្រុន និងជម្ងឺរោគមួលឱ្យបានជា ។

ព្រះគម្ពីរកិច្ចការ ២៨:៨-៩

ចំពោះខគម្ពីរទាំងប៉ុន្មានខាងលើនេះ គឺយើងអាចរាប់បញ្ចូលទាំងពួកអ្នកដឹកនាំពួកជំនុំជំនាន់ដើម ដែលបានបំពេញការងារប្រោសឱ្យជានេះដែរ ។

## VII. ការប្រោសឱ្យជាគឺជាការបើកទ្វារដំណឹងល្អ

ការប្រោសឱ្យជាគឺជាការផ្ដល់ឱ្យនូវឱកាស ដើម្បីប្រកាសដំណឹងល្អ ដល់ពួកអ្នកដែលមិនទាន់បានទទួលនូវសេចក្ដីសង្គ្រោះ ។ មុនពេលដែលមនុស្សម្នាក់អាចទទួលខុសត្រូវ ទៅនឹងដំណឹងល្អបាន នោះយើងត្រូវតែ ទីមួយ គឺឱ្យមានការចំណេញដល់ការប្រុងប្រៀបរបស់ពួកគេ ។ នៅក្នុងលោកិយដ៏ឈឺចាប់ និងគួរឱ្យឈឺក្បាលនេះ ការប្រោសឱ្យជា គឺជាប្រភពនៃការប្រុងប្រយ័ត្ន ព្រមទាំងឆាប់បានទទួលនូវការតាំងឡើង ការអស់សុពលភាពនៃព្រះបន្ទូលរបស់ព្រះ ។

**ក. ការអស្ចារ្យ ការជាប់តាម ការរស់ឡើងវិញ**

ការជួបជុំគ្នាដែលមានការអស្ចារ្យលើកទីមួយ គឺបន្ទាប់ពីការរស់ឡើងវិញ ក៏ចាប់ផ្តើមមានការប្រោសឱ្យជានេះ ។ ការអស្ចារ្យនៃការប្រោសឱ្យជាដល់មនុស្សពិការ នៅទ្វារលម្អ គឺបានបើកទ្វារសម្រាប់មនុស្ស៥០០០នាក់ បានទទួលនូវសេចក្តីសង្គ្រោះ ។

ព្រះគម្ពីរកិច្ចការ ៣:៨-១១

ព្រះគម្ពីរកិច្ចការ ៤:៤

**ខ. ចូរក្រឡេកមើលទៅសកម្មភាពលោកពេត្រុស និង យ៉ូហាន ។**

១. ពួកគេបានធ្វើសកម្មភាពជាធម្មតា ហើយក៏មានការអស្ចារ្យកើតឡើង នៅខាងក្រៅព្រះវិហារ ។

២. ពួកគេបានចាប់យកនូវការកត់ចំណាំ ទៅលើបុរសម្នាក់ ហើយក៏បាននិយាយទៅកាន់គាត់ ។ ពួកគេក៏ចាប់ប្រោសអ្នកពិការភាពនោះឱ្យបានជា ។

៣. ពួកគេមិនបានតាមមើល តាមការសុំទានប្រាក់របស់បុរសពិការនោះទេ ។

៤. ពួកគេបានឱ្យនូវអ្វីដែលពយកគេមានៈ គឺជាព្រះបន្ទូលព្រះ និងអំណាចចេស្តាក្នុងព្រះនាមព្រះយេស៊ូវ ។

៥. ពួកគេបាននិយាយដោយនូវសិទ្ធិអំណាច ។

**គ. រូបមន្តនៃការឈោងចាប់ពិភពលោក ដែលគ្មានការផ្លាស់ប្រែ ។**

**១. ព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចដោយៈ**

ក. ការបង្រៀន

ខ. ការផ្សាយដំណឹងល្អ

គ. ការប្រោសឱ្យជា

**២. ពួក១២នាក់ត្រូវបានបញ្ជូនចេញទៅៈ**

ក. ផ្សាយដំណឹងល្អ

ខ. ប្រោសឱ្យជា

គ. សម្អាតឱ្យស្អាត

ឃ. ប្រោសអ្នកស្លាប់ឱ្យរស់ឡើងវិញ ។

ង. បណ្តេញពួកវិញ្ញាណអាក្រក់

**៣. ពួក៧០នាក់ត្រូវបានបញ្ជូនចេញទៅៈ**

ក. ប្រោសអ្នកជម្ងឺឱ្យជា

ខ. ផ្សាយប្រាប់ពួកគេពី "នគរស្ថានសួគ៌ជិតមកដល់ហើយ" ។

**៤. យើងរាល់គ្នាក៏ត្រូវបានបញ្ជាឱ្យចេញបេសកកម្មៈ**

ក. ចេញទៅផ្សាដំណឹងល្អ

ខ. បណ្តេញពួកវិញ្ញាណអាក្រក់

គ. និយាយភាសាថ្មី

ឃ. អធិស្ឋានដាក់ដៃលើអ្នកជម្ងឺ ។

**៥. ការប្រោសឱ្យជា គឺមិនមែនគ្រាន់តែឱ្យមានលទ្ធភាពដល់អស់អ្នកដែលជឿប៉ុណ្ណោះទេ ។**

ព្រះយេស៊ូវទ្រង់បានសព្វព្រះហឫទ័យ ឱ្យយើងបំពេញការងារប្រោសឱ្យជាដល់អស់អ្នក ដែលមិនទាន់បានទទួលនូវសេចក្តីសង្គ្រោះផងដែរ ដូច្នេះពួកគេនឹង ដឹងពីព្រះបន្ទូលជាសេចក្តីពិត ហើយគេនឹងទទួលបាននូវសេចក្តីសង្គ្រោះ!

ព្រះគម្ពីរម៉ាថាយ ២៤:១៤

ព្រះយេស៊ូវគ្រីស្ទ ទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះ ទ្រង់បានយាងមកផែនដី ដើម្បីនាំយកនូវការប្រោសលោះដល់មនុស្សជាតិទាំងអស់ ។ ការប្រោសលោះនេះ គឺរួមបញ្ចូលទាំងការប្រោសឱ្យជាផងដែរ ។ ព្រះយេស៊ូវ ទ្រង់បានចាប់ផ្ដើមធ្វើការប្រោសឱ្យជា ដោយនូវព្រះរាជកិច្ចជាលក្ខណៈបុគ្គលរបស់ទ្រង់ ។ បន្ទាប់មក ទ្រង់ក៏បានចាប់ផ្ដើមពង្រីកឱ្យបានជាពហុគុណ ដោយការហ្វឹកហ្វឺន និងការបញ្ជាពួកសិស្សឱ្យចេញបេសកកម្ម ។ ការធ្វើរបៀបនេះ គឺនៅតែមានជាបន្ត នៅថ្ងៃរបស់យើងនេះដែរ ។ យើងជាពួកអ្នកជឿ គឺយើងត្រូវតែបានទទួល នូវព្រះរាជបញ្ជាឱ្យចេញទៅ ដោយនាំយកនូវដំណឹងល្អទៅដល់ពួកបាត់បង់ និងពិភពលោកដែលកំពុងតែក្រៀមក្រោះនោះ ។ ពួកអ្នកជឿទាំងអស់ គឺត្រូវតែបន្តធ្វើការនេះដូចៗគ្នាដូច ដែលព្រះយេស៊ូវទ្រង់បានធ្វើរួចហើយនោះ ។

## ៦. ផែនការរបស់ព្រះគឺត្រូវយើងជាថ្មីឡើងវិញ ។

មហាព្រះរាជបញ្ជាគឺត្រូវតែស្ដាប់បង្គាប់ គឺមានតែចំណែកមួយនេះទេ ។ វាគឺមិនមែនមានន័យថាត្រូវបានទទួលនូវការចែកចាយនោះទេ ។ ព្រះទ្រង់បានកែជាថ្មីឡើងវិញ ក្នុងការបំពេញការងារប្រោសឱ្យជា ដល់ពួកជំនុំជាច្រើនឆ្នាំ ដោយមានអ្នកផ្សាយដំណឹងល្អ ដែលមានការប្រោសឱ្យជាផ្សេងៗ ។ ទ្រង់សព្វព្រះហឫទ័យចង់ឱ្យពួកអ្នកជឿ បានដើរដោយនូវអំណាចចេស្ដា និងធ្វើឱ្យបានសម្រេចតាមមហាព្រះរាជបញ្ជាទាំងស្រុង ក្នុងការផ្សាដំណឹងល្អ និងការប្រោសឱ្យជា ដោយនូវអំណាចចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ទៅគ្រប់ទិសទីកន្លែង ។

## ក្រុមពិភាក្សា

១. ចូរពិភាក្សាពីរបៀបដែលព្រះយេស៊ូវ ទ្រង់បានមានភាពទាំងពីរ គឺជាមនុស្សផង ជាព្រះផង ក្នុងពេលដែលទ្រង់បានយាងមកផែនដីនេះ ។

២. ហេតុអ្វីបានជាថាមានផ្លូវតែមួយគត់ ដែលព្រះទ្រង់បានត្រូវតែជួសជុលនូវបញ្ហាអំពើបាប ទើបទ្រង់ត្រូវតែយាងមកផែនដី មកកើតជាមនុស្សនេះ?

៣. ចូរធ្វើការចែកចាយពីទីបន្ទាល់នៃពេលវេលាទាំងពីរ គឺនៅពេលដែលមានការអស្ចារ្យ និង/ឬ ការប្រោសឱ្យជា គឺជាលទ្ធផល ដែលអ្នកខ្លះត្រូវតែទទួលខុសត្រូវចំពោះដំណឹងល្អ ។

## ការសិក្សាដោយខ្លួនឯង

១. ហេតុអ្វីបានជាស្រាទំពាំងបាយជូរ បានទៅជាតំណាងឱ្យព្រះវិញ្ញាណបរិសុទ្ធ?

២. តើសំណួរអ្វីខ្លះ ដែលលោកអ្នកមាន ប្រសិនបើបានទទួលនូវមហាព្រះរាជបញ្ជានេះ? ចូរសរសេរចុះទុក ដើម្បីពិភាក្សានូវព្រះពរបន្ទាប់របស់លោកអ្នក ចំពោះក្រុម ឬមេក្រុមរបស់លោកអ្នក ។

៣. តើប្រយោគជាបន្តបន្ទាប់ទៅទៀតនេះ មានន័យដូចម្ដេចខ្លះ: "មហាព្រះរាជបញ្ជាគឺមិនមែនមានន័យថា ការចែកចាយនោះ ទេ"?

# ការប្រទានអំណាចរបស់ព្រះ
# សម្រាប់ការប្រោសឱ្យជា

## *មេរៀនទី ៤: ព្រះវិញ្ញាណបរិសុទ្ធ និងអំណាចចេស្ដារបស់ទ្រង់*

### I. គំរូរបស់លោកសាវ័កប៉ុល

ព្រះគម្ពីរ ១កូរិនថូស ២:១-៤

លោកសាវ័កប៉ុលបានបំពេញការងារ ប្រកបដោយជោគជ័យ ប៉ុន្តែ មិនមែនដោយសារលទ្ធភាពផ្ទាល់របស់គាត់នោះទេ រីឯការបង្រៀន និងការផ្សាយដំណឹងល្អរបស់គាត់ គឺបាននៅតែបន្តដោយការបើកសម្ដែងពីព្រះវិញ្ញាណ និងអំណាចចេស្ដារបស់ព្រះ ។ ពិតប្រាកដណាស់ យើងក៏ត្រូវការអំណាចចេស្ដានៃព្រះ ដែលគាត់មាននោះដែរ ប៉ុន្តែ តើត្រូវធ្វើយ៉ាងដូចម្ដេច? លោកសាវ័កប៉ុលមិនបានចង់ឱ្យសេចក្ដីជំនឿរបស់ពួកគេ បានតាំងមូលដ្ឋានលើចំណេះប្រាជ្ញា ឬអំណាចផ្ទាល់ខ្លួនរបស់គាត់នោះទេ ។

លោកសាវ័កប៉ុល ក៏បានសិក្សានៅក្រោមការបង្រៀនរបស់លោក កាម៉ាលាល ដែលជាអ្នកមានកម្រិតថ្នាក់ផ្នែកខាងទេវសាស្ត្រដ៏ខ្ពស់ នៃរយៈកាលរបស់គាត់ ។ គាត់ជាអ្នកបង្រៀនព្រះគម្ពីរដ៏ចំណាន ប៉ុន្តែ លោកសាវ័កប៉ុលចង់បានឱ្យសេចក្ដីជំនឿរបស់ពួកគេ បានតាំងលើមូលដ្ឋានអំណាចចេស្ដារបស់ព្រះវិញ គឺមិនមែនមកពីតាមរយៈចំណេះប្រាជ្ញាខាងមនុស្សនោះទេ ។

### II. អំណាចចេស្ដានៃការប្រោសឱ្យជា គឺមាននៅក្នុងជីវិតរបស់ព្រះយេស៊ូវ

ការបើកសម្ដែងពីអំណាចចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធ គឺបានចាប់ផ្ដើមនៅក្នុងព្រះរាជកិច្ចរបស់ព្រះយេស៊ូវ បន្ទាប់ពីព្រះវិញ្ញាណបរិសុទ្ធទ្រង់បានយាងមកសណ្ឋិតលើព្រះអង្គ គឺនៅពេលដែលទ្រង់បានទទួលពិធីជ្រមុជទឹក នៅទន្លេយ័រដាន ។

អំណាចចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ដែលមាននៅក្នុងព្រះយេស៊ូវ គឺត្រូវបានបញ្ជូនចូលទៅក្នុងរូបកាយរបស់អស់អ្នកណាដែលត្រូវការនូវការប្រោសឱ្យជា គឺនៅពេលដែលពួកគេបានប៉ះពាល់ដល់ព្រះអង្គដោយសេចក្ដីជំនឿនោះឯង ឬក៏នៅពេលដែលទ្រង់បានប៉ះពាល់ដល់ពួកគេ ។ សាច់រឿងរបស់ស្ត្រីម្នាក់ដែលបានត្រូវទទួលនូវការរងទុក្ខធ្លាក់ឈាម អស់រយៈពេល១២ឆ្នាំមកហើយ នោះគឺជាគំរូពីអំណាចចេស្ដានេះ ។

ព្រះគម្ពីរម៉ាកុស ៥:២៥-៣៤

អំណាចចេស្ដាដែលបានបង្ហូរមកពីព្រះយេស៊ូវ គឺជាការដ៏ពិតយ៉ាងដូច្នោះ ហើយក៏ជាការជាក់ស្ដែងដែលវាបានបណ្ដាលឱ្យទ្រង់បានឈប់ ហើយសួរថា "តើអ្នកណាពាល់អាវខ្ញុំ?" ព្រះយេស៊ូវទ្រង់បានកាន់ខ្ជាប់នូវការរកមើល អ្នកណាដែលបានពាល់ដល់ទ្រង់នោះ ។ នៅពេលដែលនាងបានសារភាព នោះគឺជាពេលដែលព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា "សេចក្ដីជំនឿរបស់នាង បានប្រោសឱ្យនាងជាទាំងស្រុងហើយ" ។

### III. អំណាចចេស្ដា ឌីណាមិស (Dunamis)

នៅក្នុងខ.៣០ ពាក្យដែលបានបកប្រែ "អំណាចវេស្ដា" គឺជាភាសាក្រិកថា "ឌីណាមិស"(Dunamis)ពាក្យឌីណាមិសគឺជាពាក្យដែលចង្អុលបង្ហាញដ៏ខ្ពស់បំផុត ។ សម្រាប់អំណាច

ចេស្តាដែលបានលេចឡើងនៅក្នុងភាសាក្រិក ។ ពិតប្រាកដណាស់ យើងមានការទំនក់ទំនងជាមួយនឹងពាក្យនេះ គឺព្រោះតែពាក្យជាភាសាអង់គ្លេសរបស់យើងថា ឌីណាមិក ឌីណាម៉ូ និងពាក្យ ឌីណាម៉ៃ ដែលចេញពីវាមកនោះឯង ។ អំណាចចេស្តាដែលបានបង្ហូរចូលមកក្នុងនាង ពីរូបកាយរបស់ព្រះយេស៊ូវ នោះគឺជាពាក្យ ឌីណាមិស ឬក៏ជាអំណាចចេស្តានៃ "ឌីណាម៉ៃ" នោះឯង ។

## ក. ការបង្ហូរចេញមកពីព្រះយេស៊ូវ គឺទៅដល់កន្លែងណាដែលទ្រង់បានយាងទៅដល់ ។

ព្រះគម្ពីរលូកា ៤:១៤

ព្រះគម្ពីរលូកា ៦:១៩

នៅពេលដែលស្ត្រីនោះបានប៉ះពាល់ព្រះយេស៊ូវទៅ នោះទ្រង់បានជ្រាបថា មានអំណាចបានហូរចេញពីទ្រង់ទៅ ។ អំណាចចេស្តានេះគឺជាការជាក់ស្តែង ប្រពលនៃអំណាចចេស្តាដែលត្រូវបានបញ្ជូនទៅ គឺតាមរយៈការប៉ះពាល់ដោយជំនឿនោះឯង ។ ការប៉ះពាល់គឺជាចំណុចនៃការទាក់ទងនោះឯង ។ ស្ត្រីនោះមានអារម្មណ៍ថា មានអំណាចចេស្តាហូរចូលមកក្នុងនាង ហើយនាងក៏បានដឹងថា នាងបានទទួលនូវការប្រោសឱ្យជាហើយ ។

## ខ. ការបង្ហូរមកតាមរយៈដៃរបស់លោកសាវ័កប៉ុល

ព្រះគម្ពីរកិច្ចការ ១៩:២-៦

លោកសាវ័កប៉ុលបានបង្រៀនអស់រយៈពេលពីរឆ្នាំ នៅក្នុងព្រះគម្ពីរកិច្ចការ ១៩:៩ និងខ.១០ ។ មានគំរូជាច្រើននៅក្នុងព្រះគម្ពីរកិច្ចការ ដែលសម្តែងអំពីការសម្តែងពីពាក្យអំណាចចេស្តាជា ឌីណាមិស នេះ នៅក្នុងការបំពេញការងាររបស់លោកសាវ័កប៉ុល ។

## គ.ការអស្ចារ្យយ៉ាងចម្លែកអស្ចារ្យ

ព្រះគម្ពីរកិច្ចការ ១៩:១១-១២

ព្រះទ្រង់បានសម្តែងពីការខុសប្រក្រតី ឬពីការអស្ចារ្យយ៉ាងចម្លែកអស្ចារ្យ តាមរយៈលោកសាវ័កប៉ុល ពីព្រោះទ្រង់គឺជាព្រះយ៉ាងចម្លែកអស្ចារ្យនោះឯង ។ ព្រះទ្រង់នៅតែសព្វព្រះហឫទ័យសម្តែងនូវការអស្ចារ្យយ៉ាងចម្លែកអស្ចារ្យ តាមរយៈដៃរបស់ពួកអ្នកជឿនៅសម័យសព្វថ្ងៃនេះ ។ អំណាចចេស្តាជា ឌីណាមិស នោះគឺនៅក្នុងដៃរបស់លោកសាវ័កប៉ុល គឺបានបញ្ចេញអំណាចតាមរយៈកំណាត់កន្សែងដៃ និងសំពត់ឱ្យចូលទៅក្នុងរូបកាយរបស់អ្នកមានជម្ងឺ និងមានការសង្កត់សង្កិននោះឱ្យបានជា ។ មានមនុស្សជាច្រើនដែលបានសួរថា: "ខ្ញុំដឹងថា អំណាចចេស្តាបានបង្ហូរចេញ តាមរយៈព្រះយេស៊ូវ និងបានបង្ហូរចេញតាមរយៈដៃរបស់អ្នកបរិសុទ្ធប៉ុល ។ ប៉ុន្តែចុះចំពោះខ្ញុំវិញ តើត្រូវធ្វើដូចម្តេចនៅថ្ងៃនេះ? បើខ្ញុំទើបតែនឹងបានមកជាអ្នកជឿដ៏សាមញ្ញយ៉ាងនេះ" ។

តាមរយៈព្រះគម្ពីរកិច្ចការ ១:៨ គឺនៅពេលដែលលោកអ្នកបានទទួលជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ នោះលោកអ្នកក៏បានទទួលនូវអំណាចចេស្តាជា ឌីណាមិស ឌីណាម៉ៃដូចគ្នាដែលមាននៅក្នុងព្រះយេស៊ូវ ហើយក៏ដូចគ្នាដែលមាននៅក្នុងដៃរបស់លោកសាវ័កប៉ុលនោះដែរ ។

## ឃ. ហេតុអ្វីបានជាខ្ញុំមិនឃើញការអស្ចារ្យនៅក្នុងជីវិតខ្ញុំ?

នៅក្នុងចម្លើយទៅនឹងសំណួរនោះ សូមយើងត្រឡប់បែរមកឯសាច់រឿងរបស់ស្ត្រីម្នាក់ដែលមាន "ជម្ងឺធ្លាក់ឈាម" ។

ព្រះគម្ពីរម៉ាកុស ៥:២៧

**១. សេចក្តីជំនឿបានចូលមក!**

ស្ត្រីនោះបានឮនិយាយពីព្រះយេស៊ូវ ។ ព្រះគម្ពីរបានចែងមកថា សេចក្តីជំនឿ គឺបានមកដោយការឮនូវព្រះបន្ទូល ។

ព្រះគម្ពីររ៉ូម ១០:១៧

នៅពេលដែលសេចក្តីជំនឿបានចូលមក ស្ត្រីនោះបានដឹងថា ប្រសិនបើនាងអាចទៅប៉ះពាល់ព្រះយេស៊ូវ នោះនាងច្បាស់ជាបានជា ។ នាងក៏បានទទួលនូវការកំណត់ថា ត្រូវតែទៅឯព្រះយេស៊ូវ ថ្វីបើនាងមានសេចក្តីកម្សោយ ខាងលក្ខណៈសរីរាង្គកាយរបស់នាងក៏ដោយ ។

**២. សេចក្តីជំនឿដោយសារការនិយាយ!**

ព្រះគម្ពីររ៉ូម ១០:៦-១០

នៅពេលដែលសេចក្តីជំនឿបានចូលមក នោះយើងនឹងតែងតែមានការនិយាយនិយាយ នូវពាក្យដែលមានពេញដោយសេចក្តីជំនឿ ដែលចេញពីមាត់យើងទៅ ។

**៣. សេចក្តីជំនឿគឺ "នៅពេលឥឡូវនេះ!"**

ព្រះគីម្ពីរហេព្រើរ ១១:១

នៅពេលដែលសេចក្តីជំនឿចូលមក តាមរយៈការស្តាប់ឮនោះព្រះបន្ទូល សាច់រឿងដែលយើងមានសង្ឃឹម និងមានសង្ឃឹមទៅថ្ងៃអនាគត នោះនឹងរឹតតែចូល ទៅក្នុងតំបន់នៃចិត្តនោះ "ក្នុងពេលឥឡូវនេះ" ។

**៤. សេចក្តីជំនឿដោយការប្រព្រឹត្ត!**

សេចក្តីជំនឿគឺតែងតែមានការប្រព្រឹត្ត ។ នៅពេលដែលសេចក្តីជំនឿបានចូលមក នោះនាងក៏បានធ្វើតាមការបញ្ជាក់ ឱ្យនាងបានធ្វើនៅកណ្តាលចំណោមហ្វូងមនុស្ស ហើយនាងក៏ខំប្រឹងធ្វើការឈោងចាប់ ដើម្បីឱ្យបានទៅប៉ះពាល់ព្រះយេស៊ូវ ។

ព្រះគម្ពីរយ៉ាកុប ២:២៦

សេចក្តីជំនឿដែលគ្មានការប្រព្រឹត្ត (គឺជាសកម្មភាពដែលស្របទៅតាម) នោះនឹងត្រូវស្លាប់ (គ្មានការអនុវត្តន៍) ។ ស្ត្រីនោះបានចាប់យកសកម្មភាព ។ នាងបានទៅដល់ និងបានប៉ះពាល់ព្រះយេស៊ូវ ដោយសេចក្តីជំនឿដែលបានចូលមក ដោយការស្តាប់ឮព្រះបន្ទូល គឺជាសេចក្តីជំនឿដែលនិយាយចេញទៅ ដោយមានសេចក្តីជំនឿ នៅពេលឥឡូវនេះនោះឯង ហើយសេចក្តីជំនឿនោះឯង ក៏បានបញ្ចេញសកម្មភាពថែមទៀត ។ នៅក្នុងមួយរំពេចភ្លាមនៃសេចក្តីជំនឿនោះឯង ដែលធ្វើឱ្យនាងបានទៅប៉ះពាល់ព្រះយេស៊ូវ គឺជាពាក្យ "ឌីណាមិស" ឬក៏ជាពាក្យអំណាចចេស្តាជា ឌីណាម៉ៃ ដែលមាននៅក្នុងព្រះយេស៊ូវ និងបានបង្ហូរចូលមកក្នុងរូបកាយរបស់នាង ហើយនាងក៏បានទទួលនូវការប្រោសឱ្យជា ។

**៥. សេចក្តីជំនឿរបស់លោកអ្នក បានបង្កើតដល់លោកអ្នកទាំងស្រុងហើយ ។** ការមានពេញដោយអំណាចចេស្តាគ្រប់ទាំងអស់ នៅក្នុងខ្សែភ្លើងអេឡិកទ្រិក គឺមានភ្លើងពេញនៅក្នុងនោះ វាមិនអាចបញ្ចេញ នូវ

សកម្មភាពបានទេ រហូតដល់ពេលគេបើកកុងតាក់វា ។ អំណាចគឺមានពេញនៅទីនោះ ប៉ុន្តែ ទាល់តែមានការចុចបើកកុងតាក់ ទើបភ្លើងនោះអាចភ្លឺទៅបាន ។

ដូច្នេះ វាមានសេចក្តីជំនឿនៅក្នុងនោះ ។ យើងត្រូវតែជ្រើសរើសអនុវត្តដោយសេចក្តីជំនឿ ជំនួសឱ្យនូវការនេះ ការជឿលើរបាយការណ៍របស់គ្រូពេទ្យ ឬក៏តាមអារម្មណ៍របស់យើង ។ ព្រះយេស៊ូវទ្រង់មានបន្ទូលថា "អ្នករាល់គ្នាត្រូវតែអធិស្ឋានដាក់ដៃលើអ្នកជម្ងឺ នោះពួកគេនឹងបានទទួលនូវការគ្របបាំង" ។

ព្រះគម្ពីរម៉ាកុស ១៦:១៨ខ

ដើម្បីឱ្យមានការពិសោធន៍ នូវការធ្វើការអស្ចារ្យក្នុងការប្រោសឱ្យជា នោះយើងត្រូវតែជឿលើព្រះយេស៊ូវ ដែលទ្រង់បានប្រាប់ពីសេចក្តីពិតនោះ ។ យើងត្រូវតែជឿលើមនុស្ស ដែលយើងបានអធិស្ឋានដាក់ដៃលើនោះ ដោយការជឿលើព្រះគម្ពីរដែលជាសេចក្តីពិតនោះ នោះនឹងមានការគ្របបាំងភ្លាមៗ ដូចជាមានការអស្ចារ្យ ឬក៏ជាការចម្រើនជឿនលឿន ដូចជាការប្រោសឱ្យជានោះឯង ។ នេះគឺមិនមែនដោយសារអំណាចចេស្តា ផ្ទាល់ខ្លួនរបស់យើងនោះទេ ។ នោះគឺមកពីយើងមានអំណាចចេស្តាដូចគ្នាជា ឌីណាមិស ឌីណាម៉ៃ នៅក្នុងយើងដូចជាពួកអ្នកជឿ ដែលបានទទួលនូវការជ្រមុជដោយព្រះវិញ្ញាណ ដែលព្រះយេស៊ូវ និងលោកសាវ័កប៉ុលបានធ្វើនៅក្នុងពួកគេ ។

## ង. អំណាចចេស្តាដូចគ្នាដែលមាននៅក្នុងលោកស្ទេផាន

គាត់គឺជាអ្នកជំនួយ (ស្មាគ្គី) នៅក្នុងព្រះវិហារក្រុងយេរូសាឡិម ។

ព្រះគម្ពីរកិច្ចការ ៦:៨

## ច. អំណាចចេស្តារបស់ព្រះបានតាំងទីលំនៅក្នុងយើង

ព្រះគម្ពីរអេភេសូរ ៣:២០

អំណាចចេស្តាដែលបានសម្តែងមកនៅទីនេះ គឺមិនមែនជាអំណាចចេស្តានៅឯស្ថានសួគ៌នោះទេ ។ វាគឺជាអំណាចដែលមាន "នៅក្នុង" យើង ។ ព្រះទ្រង់បានសព្វព្រះហឫទ័យចង់បញ្ជាក់ការអធិប្បាយ និងពីការបង្រៀនពីព្រះបន្ទូលដែលមានទីសម្គាល់និងការអស្ចារ្យ តាមរយៈអំណាចចេស្តាដែលធ្វើការនៅក្នុងយើងនោះ ។

ព្រះគម្ពីរយ៉ូហាន ៧:៣៨

ដើម្បីបំពេញការងារដោយអំណាចចេស្តារបស់ព្រះ ដែលគង់នៅក្នុងយើង នោះយើងត្រូវតែ "ជឿ" គឺត្រូវតែបើកកុងតាក់នៃសេចក្តីជំនឿ ហើយអនុញ្ញាតឱ្យការទាំងនោះ គឺជា "ទន្លេទឹករស់" នោះឯង ដែលបានបង្ហូរចេញពីចិត្តរបស់យើងដែលមានសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណារបស់ព្រះទៅនោះឯង ។

ព្រះគម្ពីរ ២កូរិនថូស ៤:៧

យើងគ្រាន់តែជាភាជនៈដែលកើតពីដីមក គឺដែលព្រះទ្រង់បានជ្រើសរើសឱ្យបានបើកសម្តែង ពីការដ៏អស្ចារ្យតាមរយៈអំណាចចេស្តារបស់ទ្រង់ ។

ព្រះគម្ពីរមីកា ៣:៨ក

ព្រះគម្ពីរសាការី ៤:៦

### ឆ. សេចក្តីអធិស្ឋានរបស់លោកសាវ័កប៉ុល

ព្រះគម្ពីរអេភេសូរ ១:១៦-២១

កម្លាំងរបស់សាតាំងទាំងអស់ បានព្យាយាមទប់ព្រះយេស៊ូវមិនឱ្យទ្រង់បានចេញពីផ្នូរមក គឺវាមិនអាចឈរនៅចំពោះអំណាចចេស្តាជា ឌីណាមិស របស់ព្រះនោះទេ ។ នោះគឺជាអំណាចដូចគ្នាដែលមាននៅក្នុងយើង ។

ព្រះគម្ពីរកិច្ចការ ៤:៣៣

ព្រះគម្ពីរកិច្ចការ ៥:១២

### ជ. ចូររង់ចាំអំណាចចេស្តា!

ពួកអ្នកជឿគឺត្រូវតែរង់ចាំនូវអំណាចចេស្តា ដែលពួកគេនឹងត្រូវបានទទួលនៅថ្ងៃទី៥០នោះ គឺមុនពេលដែលពួកគេបានព្យាយាម នឹងចេញទៅបំពេញការងាររបស់ទ្រង់ដោយនូវកម្លាំង និងអំណាចផ្ទាល់របស់ខ្លួនពួកគេនោះ ។

ព្រះគម្ពីរលូកា ២៤:៤៩

ពួកគេបានទទួលអំណាចនេះម្តងហើយ គឺពួកគេបានចេញទៅផ្សាយដំណឹងល្អ ហើយព្រះអម្ចាស់ទ្រង់ក៏នឹងធ្វើការជាមួយពួកគេ គឺជាការបញ្ជាក់ពីព្រះបន្ទូលដោយមានទីសម្គាល់ដែលជាប់តាមនោះ ។

ព្រះគម្ពីរម៉ាកុស ១៦:២០

អស់រយៈកាលជាច្រើនឆ្នាំមកហើយ ដែលខ្ញុំបានជឿលើអំណាចនោះ ប៉ុន្តែ ខ្ញុំបានបដិសេធនូវអំណាចនោះឯង ។

ព្រះគម្ពីរ ២ធីម៉ូថេ ៣:៥

ឥឡូវនេះ ខ្ញុំបានពេញដោយនូវអំណាចនៃព្រះវិញ្ញាណបរិសុទ្ធនោះហើយ យើង គឺបានដូចជាព្រះយេស៊ូវ យើងអាចនិងត្រូវតែធ្វើមិនត្រឹមតែអ្វី ដែលបានបើកសម្តែងចំពោះយើងដោយព្រះវរបិតានោះទេ គឺសម្តែងតាមរយៈព្រះវិញ្ញាណបរិសុទ្ធវិញ ។

### ឈ. មានតែព្រះយេស៊ូវទេ ដែលទ្រង់ធ្វើតាមបំណងព្រះហឫទ័យនៃព្រះវរបិតាបាន ។ យើងក៏ត្រូវតែធ្វើតាមបំណងព្រះហឫទ័យនៃព្រះវរបិតាបានដែរ ។

ព្រះគម្ពីរយ៉ូហានា ៥:១៩-២០,៣០

ដោយនូវអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះយើងក៏អាច និងត្រូវតែធ្វើតាមបំណងព្រះហឫទ័យនៃព្រះវរបិតាបានដែរ គឺយើងអាចស្តាប់បង្គាប់ដល់ទ្រង់ យើងត្រូវបើកកុងតាក់នៃសេចក្តីជំនឿ ហើយអនុញ្ញាតឱ្យអំណាចចេស្តានៃព្រះទ្រង់បានបើកសម្តែង ។

## ៣. ការធ្វើនូវកិច្ចការងាររបស់ទ្រង់

ព្រះគម្ពីរយ៉ូហាន ១៤:១២

គ្រប់ទីកន្លែងដែលព្រះយេស៊ូវទ្រង់បានយាងទៅ នោះទីសម្គាល់ និងការអស្ចារ្យនឹងជាប់តាម ។ ទ្រង់គំពុងតែបានដើរលើឈើច្រត់នៃឌីណាម៉ៃ ។ លោកអ្នកក៏អាចដើរលើឈើច្រត់នៃឌីណាមៃបានដែរ ។ អ្វីក៏ដោយ ដែលព្រះយេស៊ូវទ្រង់មានបន្ទូលមកកាន់លោកអ្នកឱ្យធ្វើអ្វីនោះចូរធ្វើចុះ ។ ការងារដែលខ្ញុំ និងព្រះយេស៊ូវអាចធ្វើបាន នោះអ្នករាល់គ្នាក៏អាចធ្វើការនោះបានដែរ ។ ប្រសិនបើលោកអ្នកបានទទួលអំណាចចេស្តាជា ឌីណាមិស នោះលោកអ្នកក៏យ៉ាងដូច្នោះដែរ ដោយនូវសេចក្តីជំនឿ ចូរធ្វើការងារដូចគ្នាដែលទ្រង់បានធ្វើចុះ ។

ព្រះគម្ពីរអេភេសូរ ៣:២០

## ក្រុមពិភាក្សា

១. តើលោកអ្នកបានតភ្ជាប់ពាក្យ "អំណាចចេស្ដា" ដែលផ្លាស់ប្ដូរបន្ទាប់ពីការសិក្សាពីអត្ថន័យនៃពាក្យ "ឌីណាមិស" របស់វាដោយរបៀបណា?

២. ចូរពិភាក្សាពីរបៀបការធ្វើការអស្ចារ្យ និងការប្រោសឱ្យជា តើដូចគ្នា ឬក៏ផ្សេងគ្នា ។

៣. តើព្រះគម្ពីរ ២ធីម៉ូថេ ៣:៥ មានន័យដូចម្ដេចដែរ? (គេមានទម្រង់ទ្រាយនៃភាពជាព្រះ ប៉ុន្តែ គេបានបដិសេធនូវអំណាចនោះទៅវិញ) ។

## ការសិក្សាដោយខ្លួនឯង

១. តើនៅពេលណា ដែលលោកអ្នកបានទទួលអំណាចចេស្ដាជា ឌីណាមិស ដូចគ្នានឹងអំណាចដែលមាននៅក្នុងព្រះយេស៊ូវនោះ? តើហេតុអ្វី?

២. ហេតុអ្វីបានជាសេចក្ដីជំនឿដែលគ្មានការប្រព្រឹត្តនោះ គឺជាជំនឿស្លាប់ (យ៉ាកុប ២:១៧)?

៣. តើលោកអ្នកអាច "ចុចបើកកុងតាក់នៃសេចក្ដីជំនឿ" នៅក្នុងជីវិតរបស់លោកអ្នកបន្ថែមទៀត ដោយរបៀបណា?

# ការប្រទានអំណាចរបស់ព្រះ សម្រាប់ការប្រោសឱ្យជា

## *មេរៀនទី ៥: ព្រះវិញ្ញាណបរិសុទ្ធ សម្រាប់គ្រប់អ្នកជឿទាំងអស់*

### I. សេចក្តីសន្យានៃព្រះវិញ្ញាណបរិសុទ្ធ

ព្រះគម្ពីរកិច្ចការ១:៤-៥

ព្រះគម្ពីរកិច្ចការ ១:៨

កុំចាកចេញពីផ្ទះដោយគ្មានខគម្ពីរនេះ ។ កុំព្យាយាមធ្វើការនេះដោយនូវអំណាច ឬកម្លាំងផ្ទាល់ខ្លួនរបស់លោកអ្នកឡើយ ។ សំណួរគឺ "តើលោកអ្នកមានអំណាចនោះនៅក្នុងជីវិតរបស់លោកអ្នកឬ?"

### II. ការទទួលអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ

#### ក.ស្រុកយូដា

ពួកអ្នកជឿនៅក្រុងយេរូសាឡិម គឺជាលើកទីមួយហើយក្នុងការទទួលនូវអំណាចចេស្តានេះ គឺដែលពួកគេបានទទួលពិធីបុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ នៅថ្ងៃទី៥០ ។

ព្រះគម្ពីរកិច្ចការ ២:១-៤

ពួកគេទាំងអស់គ្នាគឺបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយពួកគេទាំងអស់គ្នា ក៏ចាប់ផ្តើមនិយាយភាសាផ្សេងទៀត គឺជាភាសាដែលព្រះវិញ្ញាណទ្រង់បានប្រទានឱ្យដល់ពួកគេនូវសូរចេញពីមាត់មក ។ ពួកជំនុំក៏បានចាប់ផ្តើមដោយការចែករំលែកអំណាចនៃព្រះវិញ្ញាណបរិសុទ្ធនោះ ។ ប្រសិនបើយើងត្រូវតែធ្វើការងារនៃព្រះវិញ្ញាណបរិសុទ្ធ នោះយើងត្រូវតែមានអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនេះ ។

#### ខ. ស្រុកសាម៉ារី

បន្ទាប់មកទៀតពួកអ្នកស្រុកសាម៉ារី ក៏បានទទួលនូវអំណាចនេះដែរ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលថា ពួកគេត្រូវតែចាប់យកអំណាចនេះ ឱ្យទៅពួកយូដាដែលនៅក្រុងយេរូសាឡិម ហើយពួកយូដាក៏ចែកអំណាចនេះ ឱ្យទៅពួកអ្នកស្រុកសាម៉ារីទៀត ។

ព្រះគម្ពីរកិច្ចការ ៨:៥-៨

ព្រះគម្ពីរកិច្ចការ ៨:១៤-១៧

#### គ. ពួកសាសន៍ដទៃ

##### ១. ក្រុងសេសារា

ព្រះទ្រង់បានបញ្ជូនលោកសាវ័កពេត្រុស ឱ្យចាប់យកអំណាចនេះ ទៅដល់ពួកសាសន៍ដទៃ គឺបានចាប់ផ្តើមពីទីក្រុងសេសារាទៅ ។

ព្រះគម្ពីរកិច្ចការ ១០:៤៤-៤៦ក

តើពួកគេបានដឹងដោយរបៀបណា ពីសាសន៍ដទៃ ដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធនោះ? ពួកគេបានឮពីការនិយាយភាសាផ្សេងទៀត ។

##### ២. ពួកក្រុងអេភេសូរ

បន្ទាប់មក ក៏មានពួកអ្នកជឿក្រុងអេភេសូរដែលជាពួកសាសន៍ដទៃ ក៏បានទទួលនូវអំណាចនេះដែរ ។

ព្រះគម្ពីរអេភេសូរ ១៩:២-៦

**៣. សម្រាប់គ្រប់មនុស្សទាំងអស់ ដែលនៅពេញផែនដីទាំងមូល ។**

ពួកជំនុំក៏បានចាប់ផ្តើមឡើង នៅក្រុងយេរូសាឡិម ស្រុកសាម៉ារី នៅក្នុងផ្ទះរបស់លោកកូនេលាស និងនៅក្រុងអេភេសូរ ។ ដោយនូវអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះពួកជំនុំក៏បានរីកសាយគ្រាយ នៅជុំវិញពិភពលោកទាំងមូល ហើយក៏មានពេល ធ្លាក់ចុះទៅតាមជំនាន់មួយៗ ។ អំណាចនោះឯង ដែលមានដូចគ្នា គឺដែលមានលទ្ធភាព ទៅលើពួកអ្នកជឿទាំងអស់តាមជំនាន់នីមួយៗ ។ ព្រះគម្ពីរ គឺតែងតែបានចែងទុកមកជាច្រើនដងច្រើនបែបថា ពួកគេបានចាប់ផ្តើមនិយាយភាសាដទៃផ្សេងទៀត ។ ចំណុចទីមួយដែលមាននៅក្នុងព្រះគម្ពីរកិច្ចការ ក៏បានចែងមកថា ពួកគេទាំងអស់គ្នាបាននិយាយជាភាសាដទៃផ្សេងទៀត គេធ្វើការអស្ចារ្យមាត់របស់ពួកគេ ។ នោះគឺជាភស្តុតាងដែលព្រះគម្ពីរបានបញ្ជាក់ថា ពួកគេបានទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងបានចែករំលែកអំណាចនោះ ដើម្បីធ្វើទីបន្ទាល់ពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ រហូតមកដល់សព្វ ថ្ងៃនេះ ។

**ឃ.ការចាក់បំពេញបន្ថែម នូវព្រះវិញ្ញាណនៃសេចក្តីក្លាហាន**

អស់អ្នកដែលបានទទួលនូវចាក់បំពេញបន្ថែម នូវព្រះវិញ្ញាណបរិសុទ្ធ នោះនឹងអាចទទួលនូវ "ការចាក់បំពេញ" ថ្មីៗ ។

ព្រះគម្ពីរកិច្ចការ ៤:២៩-៣១

អស់អ្នកដែលបានទទួលនូវការចាក់បំពេញ ដោយនូវព្រះវិញ្ញាណបរិសុទ្ធ នៅថ្ងៃទី៥០ នោះគ្រប់គ្នាទាំងអស់នឹងបានទទួលនូវការបំពេញទៀត ដែលរួមបញ្ចូលទាំងលោកសាវ័កពេត្រុស និងយ៉ូហាន ដែលទើបតែមានការបំពេញការងារប្រោសឱ្យជាដល់មនុស្សពិការ ព្រមទាំងបានផ្សាយដំណឹងល្អដល់មនុស្សរាប់ពាន់នាក់ ឱ្យបានចូលមកក្នុងនគរ ។ ការចាក់បំពេញថ្មីៗនេះ គឺបានមកដោយមាន "ព្រះវិញ្ញាណនៃសេចក្តីក្លាហាន" ។ ព្រះគម្ពីរសុភាសិត ២៨:១ខ ។

**ង. ការទូលសូម និងការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ**

ព្រះគម្ពីរលូកា ១១:១៣

គ្រប់ទាំងអស់ដែលយើងត្រូវតែធ្វើ គឺជាការទូលសូមដោយសេចក្តីជំនឿ ការជឿនិងការទទួលនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ ជីវិតរបស់លោកអ្នកនឹងមិនដែលបានដូចដើមជាបន្តទៅទៀតឡើយ ។

**១. ព្រះយេស៊ូវទ្រង់នឹងធ្វើពិធីជ្រមុជឱ្យលោកអ្នក ។**

ព្រះគម្ពីរម៉ាកុស ១:៧-៨

**២. ការបើកសម្តែងពីការនិយាយភាសាដទៃ**

នៅពេលដែលយើង បានទទួលនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ នោះយើងគឺដូចជាពួកអ្នកជឿដទៃទៀត នៅថ្ងៃទី៥០ គឺត្រូវតែបើកមាត់ និងចាប់ផ្តើមនិយាយ ។ ពេលដែលយើងចាប់ផ្តើមបង្កើតនូវសម្លេងទីមួយ ដោយសេចក្តីជំនឿ នោះការអស្ចារ្យនឹងចាប់ផ្តើមពីមាត់របស់យើង ហើយយើងនឹងបានឮក្នុងមួយរំពេចភ្លាមៗ គឺជាការនិយាយដោយខ្លួនឯងនូវ "ភាសាដទៃ" ជាអធិធម្មជាតិនោះ ។

ព្រះគម្ពីរម៉ាកុស ១៦:១៧

ចំពោះ "ភាសាដទៃ" ទាំងនេះគឺជាភាសាស្ថានសួគ៌ ឬក៏ជា "ភាសាទេវតា" ។

ព្រះគម្ពីរ ១កូរិនថូស ១៣:១

ពួកគេក៏អាចនិយាយ ជាភាសាមនុស្សជាតិផងដែរ គឺជាភាសាដែលពួកគេមិនបានដឹងពីមុនមក ប៉ុន្តែអ្នកដទៃ អាចស្តាប់ឮ និងយល់បាន ។

ព្រះគម្ពីរកិច្ចការ ២:៥-៦

យើងត្រូវតែចងចាំថា យើងមិនអាចនិយាយដោយបបូរមាត់របស់យើងនៅបិទបានទេ ។ យើងត្រូវតែបើកបបូរមាត់យើងឡើង ហើយចាប់ផ្តើមនិយាយ ។ ចាប់តាំងពីយើងមិនអាចនិយាយបានភាសាពីរក្នុងពេលតែមួយ យើងទាំងអស់គ្នាត្រូវការធ្វើការ គឺត្រូវតែបង្កើតសម្លេងឡើង ។ នៅថ្ងៃទី៥០ គឺជាថ្ងៃដែលពួកគេទាំងអស់បានចាប់ផ្តើមនិយាយ ។ នោះគឺជាចំណែករបស់យើងហើយ ។ ព្រះទ្រង់បានធ្វើឱ្យយើងជឿ គឺក្នុងពេលមួយរំពេចភ្លាម១ ដែលយើងមានសេចក្តីជំនឿនោះឯង ។ ទ្រង់បានប្រទានដល់ពួកគេនូវ "ស្នូរចេញពីមាត់" ហើយការអស្ចារ្យក៏ចាប់ផ្តើមមានឡើងនៅក្នុងមាត់របស់ពួកគេ ។ នៅពេលដែលយើងបើកមាត់របស់យើង ដោយសេចក្តីជំនឿ ហើយក៏ផ្តើមបង្កើតសម្លេងទាំងនោះ គឺវាដូចជាលោកសាវ៉កពេត្រុស ដែលបានឈានជំហានចេញពីទូក និងដើរពីលើទឹកជាមួយនឹងព្រះយេស៊ូវដូច្នោះដែរ ។ លោកសាវ៉កពេត្រុស ដោយមានការស្តាប់បង្គាប់ ក៏បានធ្វើនូវចំណែករបស់គាត់ និងបានឈានជំហានចេញពីទូកនោះមក ។ ក្នុងពេលមួយរំពេចភ្លាមនោះ ព្រះទ្រង់ក៏បានធ្វើនូវចំណែករបស់ទ្រង់ ។ ការធ្វើការអស្ចារ្យក៏បានសម្រេច ហើយព្រះវិញ្ញាណបរិសុទ្ធក៏បានបង្កើតទឹក ឱ្យមានធាតុរឹងនៅពីក្រោមជើងរបស់លោកសាវ៉កពេត្រុស ។ ម្យ៉ាងទៀត នៅពេលដែលយើងចាប់ផ្តើមនិយាយ នោះព្រះវិញ្ញាណបរិសុទ្ធក៏បានចាប់យកនូវចំណែករបស់ទ្រង់ ព្រមទាំងបានប្រទានឱ្យ នូវភាសាថ្មីដែលជាភាសាអធិធម្មជាតិរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ ប៉ុន្តែ ព្រះទ្រង់មិនអាចធ្វើនូវចំណែករបស់ទ្រង់បានទេ គឺលុះត្រាតែយើងបានធ្វើនូវចំណែករបស់យើងជាមុនសិន ។

## ៣. សំណូមពរអធិស្ឋានឱ្យបានទទួល

តើលោកអ្នកបានត្រៀមខ្លួននឹងទទួល នូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ឥឡូវនេះហើយឬនៅ? ឬក៏ប្រសិនបើបានទទួលហើយ តើលោកអ្នកបានត្រៀមខ្លួន នឹងទទួលព្រះវិញ្ញាណបរិសុទ្ធបន្ថែមថ្មី១ទៀតហើយឬនៅ? បន្ទាប់មក ខ្ញុំនឹងដឹកនាំលោកអ្នកនៅក្នុងសេចក្តីអធិស្ឋាននេះ ។ សូមឱ្យលោកអ្នកបានអធិស្ឋានតាមខ្ញុំ ។ ព្រះយេស៊ូវអង្គទ្រង់នឹងជ្រមុជលោកអ្នក ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយបន្ទាប់មក លោកអ្នកនឹងបើកមាត់របស់លោកអ្នក ហើយចាប់ផ្តើមនិយាយភាសាថ្មី ។

សេចក្តីអធិស្ឋានៈ

"ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ នៅក្នុងព្រះនាមព្រះយេស៊ូវ ទូលបង្គំទូលសូមដល់ព្រះអង្គ នូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។ ឱព្រះយេស៊ូវ

អើយ ទូលបង្គំទូលសូមឱ្យព្រះអង្គបានជ្រមុជទូលបង្គំ ដោយនូវព្រះវិញ្ញាណបរិសុទ្ធផង ។ ទូលបង្គំសូមទទួលយកនូវអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធក្នុងពេលឥឡូវនេះ ។ ទូលបង្គំសូមលើកដៃចុះចូលចំពោះទ្រង់ ហើយទូលបង្គំសូមនិយាយថា សូមបំពេញទូលបង្គំឥឡូវនេះ ដោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គផង ។ ទូលបង្គំសូមទទួលយកនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ ហើយទូលបង្គំសូមឱ្យបានទទួល ដូចជានៅថ្ងៃទី៥០នោះផង សូមឱ្យទូលបង្គំបានបើកបបូរមាត់ឡើង នៅពេលឥឡូវនេះ ព្រមទាំងចាប់ផ្ដើមសរសើរដល់ព្រះអង្គ ជាភាសាមួយថ្មីដែលមកពីស្ថានសួគ៌ផង" ។ (ចូរនៅតែបន្តសរសើរតម្កើងដល់ព្រះអង្គ ដោយនូវភាសាថ្មីរបស់លោកអ្នក ដែលមកពីស្ថានសួគ៌ រហូតដល់លោកអ្នកមានអារម្មណ៍ថា មានការពេញលេញហើយ ក្នុងការបញ្ចេញនូវការសរសើរ ដោយនូវវិញ្ញាណរបស់លោកអ្នកនោះ) ។

## ៤. តើបន្ទាប់ទៀតគឺជាអ្វី?

ឥឡូវនេះ អារក្សវាកំពុងតែជ្រួលច្របល់ជាទីបំផុត ។ វាដឹងថា លោកអ្នកទើបតែនឹងបានទទួលនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ វានឹងប្រាប់លោកអ្នកថា គ្មានអ្វីកើតឡើងទេ ។ អារក្សគឺជាអ្នកកុហក ។ លោកអ្នកអាចបញ្ជាក់ភស្តុតាងថា ឥឡូវនេះអញបានទទួលអំណោយទាន ជាភាសាដទៃ គឺជាភាសាដែលមកពីស្ថានសួគ៌ហើយ គឺនិយាយពាក្យនេះដោយខ្លាំងៗ ។ (លោកអ្នកទើបតែបានបញ្ជាក់ថា អារក្ស គឺជាអ្នកកុហក) ។

## ៥. ភាសានៃការសរសើរ និងអធិស្ឋាន

លោកអ្នកមានអំណាចចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធ និងភាសាដទៃដែលមកពីស្ថានសួគ៌ហើយ ។ នេះគឺជាភាសានៃការសរសើរដែលគ្មានកំណត់ ។ វាក៏ជាភាសានៃការអធិស្ឋាន ដែលគ្មានកំណត់ដែរ ។ នៅក្នុងភាពជាធម្មជាតិ យើងមិនអាចដឹងពីរបៀបអធិស្ឋានពីស្ថានការណ៍ដ៏ពិតនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលយើងអធិស្ឋានដោយនូវភាសាថ្មីដែលមកពីស្ថានសួគ៌របស់យើង នោះព្រះវិញ្ញាណបរិសុទ្ធក៏អធិស្ឋាន តាមរយៈវិញ្ញាណរបស់យើង គឺទៅតាមបំណងព្រះហឫទ័យដ៏គ្រប់លក្ខណ៍នៃព្រះវរបិតាផងដែរ ។ ដូច្នេះ រឿងរ៉ាវដែលមានពេញដោយអំណាចព្រះចេស្ដាបានកើតឡើង គឺនៅពេលដែលយើងអធិស្ឋានដោយព្រះវិញ្ញាណ ដែលនៅក្នុងភាសាថ្មីមកពីស្ថានសួគ៌របស់យើងនោះឯង ។ លោកអ្នកអាចអធិស្ឋានទៅតាមបំណងព្រះហឫទ័យនៃព្រះវរបិតា នៅក្នុងស្ថានការណ៍ណាមួយបាន ។

ព្រះគម្ពីរ ១កូរិនថូស ១៤:១៤

ព្រះគម្ពីររ៉ូម ៨:២៦-២៧

ចូរចំណាយពេលអធិស្ឋាន ដោយភាសាថ្មីដែលមកពីស្ថានសួគ៌របស់លោកអ្នក សម្រាប់ដល់ពួកអ្នកដែលមិនទាន់បានទទួលនូវសេចក្ដីសង្គ្រោះ នៅពេលឥឡូវនេះ។

**៦. ការច្រៀងចម្រៀងខាងឯវិញ្ញាណ**

ព្រះគម្ពីរ ១កូរិនថូស ១៤:១៥

នៅពេលដែលយើង "ច្រៀងចម្រៀងខាងឯវិញ្ញាណ" នោះព្រះវិញ្ញាណបរិសុទ្ធ មិនត្រឹមតែប្រទានឱ្យយើង នូវពាក្យសម្ដីប៉ុណ្ណោះទេ គឺទ្រង់ថែមទាំងប្រទានឱ្យយើងរោហាឃ្លោងឃ្លាថែមទៀតផង ។ ចូរធ្វើការចំណាយពេលឥឡូវនេះ ដើម្បីចូលរួមនឹងសម្លេងរបស់លោកអ្នកជាមួយនឹងពួកទេវតា ដែលនៅស្ថានសួគ៌ ដែលកំពុងតែច្រៀងចម្រៀងសរសើរដល់ព្រះ នៅក្នុងសម្លេងភាសាថ្មី ដែលនៅស្ថានសួគ៌របស់លោកអ្នកនោះដែរ ។

**៧. ការរស់នៅដោយវិញ្ញាណ**

ព្រះគម្ពីរកាឡាទី ៥:២៥

ចូរចំណាយពេលអធិស្ឋាន សរសើរតម្កើង និងថ្វាយបង្គំដល់ព្រះ ដោយនូវភាសាថ្មីដែលនៅស្ថានសួគ៌ ដូចជាលោកអ្នកបានធ្វើដំណើរ នៅក្នុងជីវិតប្រចាំថ្ងៃដែរ ។ ក្រៅពីនេះ ចិត្តរបស់លោកអ្នកគឺបានបង្ហូរមកដូចជាទន្លេទឹករស់នោះដែរ ។

ព្រះគម្ពីរយ៉ូហាន ៧:៣៨

លោកអ្នកកំពុងតែរស់នៅ និងដើរដោយនូវព្រះវិញ្ញាណ ។ ឥឡូវនេះ លោកអ្នកបានបំពេញដោយនូវព្រះវិញ្ញាណ ព្រមទាំងបានបំពេញដោយនូវភាពក្លាហានរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ គឺឥឡូវហើយនេះលោកអ្នកបានឈើច្រត់ នៃអំណាចចេស្ដាជាឱណាមិស ឱណាម៉ែ របស់ព្រះ ។ លោកអ្នកនឹងមិនដូចពីមុនឡើយ ។

**III. ការអធិស្ឋានដាក់ដៃលើ**

**ក. លោកម៉ូសេបានផ្ទេរវិញ្ញាណនៃប្រាជ្ញា ឱ្យទៅលោកយ៉ូស្វេ**

ព្រះគម្ពីរចោទិយកថា ៣៤:៩

**ខ. អំណោយទាន ដែលបានចែករំលែកទៅលោកធីម៉ូថេ ដោយការអធិស្ឋានដាក់ដៃលើ និងការថ្លែងទំនាយ**

ព្រះគម្ពីរ ១ធីម៉ូថេ ៤:១៤

**គ. លោកសាវ័កប៉ុល បានចែករំលែកអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ**

ព្រះគម្ពីរកិច្ចការ ១៩:៦

**ឃ. ព្រះយេស៊ូវ ទ្រង់បានបំពេញព្រះរាជកិច្ចប្រោសឱ្យជា ដោយការអធិស្ឋានដាក់របស់ទ្រង់ពីលើ ។**

**១. អ្នកកើតរោគឃ្លង់**

ព្រះយេស៊ូវទ្រង់បានបំផ្លាស់បំប្រែ ដោយនូវសេចក្ដីមេត្តាករុណា ។ ទ្រង់បានបំពេញព្រះរាជកិច្ចប្រោសឱ្យជា ដល់អ្នកកើតរោគឃ្លង់ ដោយបានអធិស្ឋានដាក់ព្រះហស្តរបស់ទ្រង់ទៅលើគាត់ ។

ព្រះគម្ពីរម៉ាកុស ១:៤០-៤១

**២. ព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ច ដល់កូនស្រីរបស់លោកយ៉ៃរ៉ុស ។**

ព្រះគម្ពីរម៉ាកុស ៥:៤១

បន្ទាប់ពីបានដោះអ្នក ដែលមិនជឿចេញហើយ នោះព្រះយេស៊ូវទ្រង់បានចាប់លើកនាងឡើង ដោយព្រះហស្ត ហើយមានបន្ទូលថា "ចូររស់ឡើង" ។

### ៣. មនុស្សគថ្លង់

ព្រះគម្ពីរម៉ាកុស ៧:៣២-៣៥

ទ្រង់បានដាក់ម្រាមដៃរបស់ទ្រង់ ទៅក្នុងត្រចៀករបស់គាត់ ។ បន្ទាប់មក ក៏បានពាល់អណ្តាតគាត់ ។ ព្រះយេស៊ូវទ្រង់បានងើយមើលទៅស្ថានសួគ៌ រួចក៏មាន បន្ទូលថា "ចូរបើកឡើង!"

កំណត់ចំណាំៈ ព្រះយេស៊ូវទ្រង់មិនដែលបានប្រើពាក្យអធិស្ឋានវែង គឺនៅពេលដែលទ្រង់បានបំពេញព្រះរាជកិច្ចប្រោសឱ្យជានោះ ។ ព្រះយេស៊ូវទ្រង់ប្រើពាក្យបញ្ជាខ្លីៗ គឺទ្រង់មានបន្ទូលដោយមានអំណាច ។ យើងក៏ដូច្នោះដែរ គឺយើងនឹងបានឃើញលទ្ធផលច្រើនថែមទៀត ប្រសិនបើយើងធ្វើការឱ្យដូចជាព្រះយេស៊ូវទ្រង់បានធ្វើ ។

ហើយក៏ចូរចងចាំផងដែរថា ព្រះយេស៊ូវទ្រង់មានបន្ទូល ថា "ចូរចាំយាមហើយអធិស្ឋានចុះ" ។

ព្រះគម្ពីរម៉ាកុស១៣:៣៣

មានមនុស្សជាច្រើនបានបិទភ្នែក គឺនៅពេលដែលបំពេញការងារប្រោសឱ្យជា ប្រហែលជាដោយសារទំនៀមទម្លាប់ ឬក៏ដោយសារតែពួកគេមានការខ្លាចថា ការនោះគឺមិនអាចកើតបានឡើយ។ ប្រសិនបើលោកម៉ាថាយ ម៉ាកុស និងយ៉ូហាន បានបិទភ្នែករបស់ពួកគេ ក្នុងគ្រប់ពេលដែលព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចប្រោសអ្នកជម្ងឺឱ្យជា នោះនឹងគ្មានការធ្វើការអស្ចារ្យណាមួយ បានកត់ត្រាទុកនៅក្នុង "ដំណឹងល្អ" នោះឡើយ ។ ពួកគេអាចនឹងមានការបាត់បង់ពីគ្រប់អស់ទាំងការអស្ចារ្យ នៃការប្រោសឱ្យជាហើយ ។ យើងនៅតែបើកភ្នែករបស់យើងដដែលពីព្រោះ យើងកំពុងតែអនុវត្តដោយសេចក្តីជំនឿដោយសេចក្តីសង្ឃឹមថា នឹងមានការបើកសម្តែងពីការប្រោសឱ្យជានោះបាន ។ លោកអ្នកមិនអាចអនុវត្តបានដោយមានការសង្ស័យនោះទេ ហើយសេចក្តីជំនឿ គឺនៅពេលតែមួយនោះឯង ។ នៅពេលដែលយើងបានបំពេញការងារ ដោយសេចក្តីជំនឿដូចជាព្រះយេស៊ូវមានដែរ នោះយើងនឹងមានការពិសោធន៍ និងមានលទ្ធផលប្រសើរលើសទៅទៀត ។

ព្រះគម្ពីរម៉ាកុស ១៣:៣៣

### ៤. លោកសាវ័កប៉ុលនៅទីក្រុងម៉ាលេត

ព្រះគម្ពីរកិច្ចការ២៨:៧-៨

មុនពេលដែលលោកសាវ័កប៉ុល បានបំពេញការងារទៅដល់គេ នោះគាត់បានអធិស្ឋាន ។ បន្ទាប់មក គាត់ក៏បានអធិស្ឋានដាក់ដៃលើគេ ហើយគេក៏បានទទួលនូវការប្រោសឱ្យជា ។ ហេតុអ្វីបានជាគាត់ត្រូវអធិស្ឋានជាទីមួយ? គឺប្រហែលជាគាត់បានអធិស្ឋាន ទូលសូមសម្រាប់ពាក្យសម្តីនៃចំណេះចេះស្ទាត់ ក្នុងការបំពេញការងារប្រោសឱ្យជាដល់មនុស្សនោះ ។ បន្ទាប់មក ក៏មានការស្តាប់បង្គាប់ចំពោះពាក្យសម្តីនៃចំណេះចេះស្ទាត់នោះ គាត់ក៏បានបំពេញការងារប្រោសឱ្យជាទៅដល់គេ ដោយការអធិស្ឋានដាក់ដៃលើនោះ ។ ព្រះយេស៊ូវ ឬក៏អស់ពួកអ្នកជឿដំបូង គឺមិនដែលបានបំពេញការងារប្រោសឱ្យជា

ដោយការអធិស្ឋាន និងទូលសូមដល់ព្រះ ឱ្យមានការប្រោសឱ្យជាដល់មនុស្សនោះទេ ។

**៥. យើងត្រូវតែ "ប្រោសអ្នកជម្ងឺឱ្យជា" ។**

ព្រះយេស៊ូវទ្រង់បានបញ្ជាក់ការនេះ យ៉ាងច្បាស់ថា យើងគឺដូចជាពួកសិស្សរបស់ទ្រង់ដែរ គឺត្រូវតែ "ប្រោសអ្នកជម្ងឺឱ្យជា" ។

ព្រះគម្ពីរម៉ាថាយ ១០:៨

**៦. ការប្រោសឱ្យជាគឺជាការអធិស្ឋានដាក់ដៃលើ**

យើងដឹងថា យើងមិនមែនកំពុងតែបំពេញការងារប្រោសឱ្យជា ដោយអំណាច ឬសមត្ថភាពផ្ទាល់ខ្លួនរបស់យើងទេ ។ ទោះជាយ៉ាងណាក៏ដោយ ឥឡូវនេះយើងដឹងថា វាគឺជាការប្រោសឱ្យជា ដោយនូវអំណាចចេស្តារបស់ព្រះ ដែលមាននៅក្នុងយើងនោះឯង ។ យើងគឺដូចជាព្រះយេស៊ូវ គឺត្រូវតែនិយាយដោយនូវសិទ្ធិអំណាច ដោយការប្រើពាក្យពេចន៍ខ្លីៗ ជាពាក្យពេចន៍បញ្ជា គឺដូចជាយើងបានចុចកុងតាក់នៃសេចក្តីជំនឿ បើកនូវអំណាចនៃការប្រោសឱ្យជារបស់ព្រះ វិញ្ញាណបរិសុទ្ធឱ្យបង្ហូរចូលមក ក្នុងរូបកាយរបស់ពួកគេនោះឯង ។

ព្រះគម្ពីរម៉ាកុស ១៦:១៨ខ

នៅពេលដែលយើងអធិស្ឋាន ដាក់ដៃលើអ្នកជម្ងឺ នោះយើងត្រូវតែបង្កើតនូវចំណុចនៃការទំនាក់ទំនងនេះ ។ វាគឺដូចជាខ្សែភ្លើងដ៏ក្តៅទាំងពីរ ដែលបានចូលមករួមគ្នា ដើម្បីឱ្យកម្លាំងភ្លើងនោះអាចបង្ហូរចេញមក ។ បន្ទាប់មក យើងក៏ចុចបើកកុងតាក់នៃសេចក្តីជំនឿ ហើយបញ្ចេញនូវពាក្យ ឌីណាមិស (ឌីណាម៉ៃ) គឺជាអំណាចចេស្តានៃការប្រោសឱ្យជារបស់ព្រះវិញ្ញាណបរិសុទ្ធ ឱ្យបានបង្ហូរចូលមកក្នុងចំណែកនៃរូបកាយរបស់ពួកគេ ដែលគេត្រូវការការប្រោសឱ្យជានោះ ។

**៧. ការធ្វើការងាររបស់ព្រះយេស៊ូវ**

ព្រះគម្ពីរយ៉ូហាន ១៤:១២

ព្រះរាជកិច្ចរបស់ព្រះយេស៊ូវ គឺ "ត្រូវបានបង្គ្រប់ហើយ" ។ រីឯ "ការងារ" របស់យើងវិញ ក៏ត្រូវបានចាប់ផ្តើមឡើងដែរ ។ យើងគឺដូចជាព្រះយេស៊ូវ យើងត្រូវតែចាប់ផ្តើមបំពេញការងារ ដោយនូវសិទ្ធិអំណាច និងអំណាចចេស្តា ដែលមាននៅក្នុងយើង ។ ព្រះយេស៊ូវទ្រង់បានធ្វើការនេះហើយ គឺដែលទ្រង់ជាមនុស្សបានបំពេញដោយនូវអំណាចចេស្តា នៃព្រះវិញ្ញាណបរិសុទ្ធហើយ ។ ប្រសិនបើព្រះយេស៊ូវទ្រង់អាចធ្វើការនេះបាន យើងក៏អាច និងត្រូវតែធ្វើដោយមានការស្តាប់បង្គាប់ដល់ទ្រង់ ដោយនិយាយថា "ខ្ញុំក៏អាចធ្វើការនេះបានដែរ!"

***សូមព្រះប្រទានពរដល់លោកអ្នក ហើយលោកអ្នកក៏ដែរនឹងមើលឃើញនូវការអស្ចារ្យកាន់តែច្រើនឡើងៗ ។***

## ក្រុមពិភាក្សា

១. ហេតុអ្វីបានជាយើងនឹងមិនអាចមើលឃើញ បន្ថែមទៀតនូវលទ្ធផល ក្នុងពេលដែលយើងបំពេញការងារប្រោសឱ្យជា ប្រសិនបើប្រើពាក្យបញ្ជាខ្លីៗ ដែលបាននិយាយដោយសិទ្ធិអំណាចនោះ?

២. ក្នុងពេលអតីតកាល ប្រសិនបើលោកអ្នកបានអធិស្ឋានសម្រាប់ការងារប្រោសឱ្យជា ដោយបិទភ្នែករបស់លោកអ្នក នោះចូរចែកចាយពីហេតុផលរបស់អ្នក មូលហេតុអ្វីបានជាលោកអ្នកបានបិទភ្នែកនោះ ។

៣. តើលោកអ្នកគិតយ៉ាងដូចម្តេច ចំពោះប្រយោគជាបន្តបន្ទាប់: "ព្រះយេស៊ូវទ្រង់មិនដែលបំពេញព្រះរាជកិច្ច នៃការប្រោសឱ្យជា ដោយការអធិស្ឋានទូលសូមដល់ព្រះឱ្យទ្រង់បានប្រោសមនុស្សឱ្យជា"?

## ការសិក្សាដោយខ្លួនឯង

១. គោលបំណងអធិស្ឋាន និងច្រៀងបន្ថែមទៀតដោយនូវភាសារបស់អ្នកដែលមកពីស្ថានសួគ៌ ជារៀងរាល់ថ្ងៃ ។ ប្រសិនបើលោកអ្នក មិនដែលធ្វើយ៉ាងដូច្នោះពីមុនមកទេ ចូរព្យាយាមច្រៀងចម្រៀងខាងឯវិញ្ញាណឥឡូវនេះ ។

២. ហេតុអ្វីបានជាការសំខាន់ ដែលព្រះយេស៊ូវទ្រង់មានបន្ទូលឱ្យ "ចាំយាមហើយអធិស្ឋាន ... " (ម៉ាថាយ ២៦:៤១)?

៣. ចូរបង្កើតចំណុចមួយ នៅពេលលោកអ្នកអធិស្ឋាន និងបំពេញការងារប្រោសឱ្យជាដល់អ្នកណាម្នាក់នោះ ដើម្បីរក្សាភ្នែកលោកអ្នកឱ្យនៅតែបើកដដែល ។ ចូរសង្ឃឹមថាការបើកសម្តែងពីការប្រោសឱ្យជា នឹងកើតមានឡើង ។

# ការប្រទានអំណាចរបស់ព្រះ សម្រាប់ការប្រោសឱ្យជា

### *មេរៀនទី ៦: ការបំពេញការងារដោយនូវអំណាចចេស្តា*

## I. គោលដៅរបស់យើង

ខ្ញុំចង់បង្រៀនលោកអ្នក ឱ្យអនុវត្តនូវមធ្យោបាយទាំងឡាយក្នុងការបំពេញការងារ ដោយអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនេះ ។ យើងត្រូវតែថ្វាយខ្លួនទាំងស្រុងទៅព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឱ្យបានមានការស្រេកឃ្លានដល់ព្រះជាបន្ថែមទៀត និងស្វែងរកព្រះអង្គយ៉ាងអស់ពីដួងចិត្ត ។

ព្រះគម្ពីរអេភេសូរ ៤:១១-១២

ដូច្នេះ ការងាររបស់ខ្ញុំគឺត្រូវតែជាឧបករណ៍ដល់អ្នកជឿគ្រប់រូប ដើម្បីធ្វើការងារ ក្នុងការបង្រៀនដល់អ្នកជឿគ្រប់រូបពីរបៀបដែលត្រូវធំពេញការងារប្រោសអ្នកឈឺឱ្យជា ដូចជាពួកគេបានធ្វើការថ្វាយព្រះយេស៊ូវដែរ ។

## II. ការដឹកនាំដោយព្រះវិញ្ញាណ

នៅក្នុងព្រះគម្ពីរយ៉ូហាន យើងបានមើលឃើញថា ព្រះយេស៊ូវទ្រង់ត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ គឺដែលទ្រង់បានបំពេញព្រះរាជកិច្ចប្រោសឱ្យជានោះឯង ។ នៅក្នុងស្រះបេតថេសដា មានមនុស្សជាច្រើនដែលត្រូវការការប្រោសឱ្យជា ។ ទោះជាយ៉ាងណាក៏ដោយ ពេលព្រះយេស៊ូវទ្រង់ជ្រាបដោយព្រះវិញ្ញាណបរិសុទ្ធនោះ ទ្រង់បានទទួលការដឹកនាំជាមនុស្សជាតិសុទ្ធសាធ ។ ប៉ុន្តែ ព្រះយេស៊ូវទ្រង់បានធ្វើគ្រប់យ៉ាងតាមតែអ្វីដែលទ្រង់បានឃើញព្រះវរបិតាទ្រង់ធ្វើប៉ុណ្ណោះ ។ យើងក៏ដូច្នោះដែរ គឺត្រូវតែបានទទួលការដឹកនាំ ដោយព្រះវិញ្ញាណបរិសុទ្ធ ទៅដល់អស់អ្នកណាដែលយើងត្រូវតែបំពេញការងារប្រោសឱ្យជា ។

ព្រះគម្ពីរយ៉ូហាន ៥:១-៩

## III. ការឆ្លើយតបទៅលើការអនុវត្តន៍

ជាបន្តបន្ទាប់គឺជាការឆ្លើយតបទៅលើការអនុវត្តន៍ ដើម្បីប្រើប្រាស់នូវការបំពេញការងារប្រោសអ្នកឈឺឱ្យជា:

### ក. ពេលដែលមានលទ្ធភាព សាកាំងនឹងសំដៅទៅចំពោះមុខមនុស្ស ដែលបានចូលមកបំពេញការងារនោះ ។

### ខ. សួរដល់ពួកគេ:

"តើដែលអ្នកកំពុងតែជឿនេះ បានទទួលអ្វីមកពីព្រះ?" ជំនួសឱ្យនូវការសួរដល់ពួកគេនេះ តើអ្វីទៅដែលខុស លោកអ្នកក៏កំពុងតែសួរនូវសំណួរតាមមធ្យោបាយរបៀបនោះថា តើនឹងបានទទួលអ្វី ដើម្បីបញ្ជាក់ពីសេចក្តីជំនឿរបស់ពួកគេនោះឯង ។

ព្រះគម្ពីរម៉ាថាយ ៩:២២ខ

### គ. យ៉ាងហោចណាស់ក៏ត្រូវមានចម្លើយដែរ

ការទទួលខុសត្រូវរបស់លោកអ្នកគួរតែជា: "នោះគឺជាការងាយស្រួលសម្រាប់ព្រះ!" ចំពោះព្រះ គឺទ្រង់អាចធ្វើគ្រប់ការទាំងអស់បាន ។

ព្រះគម្ពីរម៉ាថាយ ១៩:២៦

ព្រះគម្ពីរម៉ាកុស ៩:២៣

### ឃ. ការអធិស្ឋានដាក់លើពួកគេ

